ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

# គោលការណ៍ណែនាំ សម្រាប់អ្នកសម្របសម្រួល
# ស្តីពី
# បច្ចេកទេសចិញ្ចឹមជ្រូកជាលក្ខណៈគ្រួសារ



២០១២

# គោលការណ៍ណែនាំសម្រាប់អ្នកសម្របសម្រួល ស្តីអំពី បច្ចេកទេសចិញ្ចឹមជ្រូកជាលក្ខណៈគ្រួសារ

**បោះពុម្ពផ្សាយដោយ** ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទនៃព្រះរាជាណាចក្រកម្ពុជា
បោះពុម្ពនៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០១២ (បោះពុម្ពលើកទី១)
បោះពុម្ព និងតម្លើងជាសៀវភៅដោយ ក្រុមហ៊ុន Invent កម្ពុជា

ឯកសារនេះត្រូវបានចងក្រង និងបោះពុម្ពផ្សាយក្រោមការឧបត្ថម្ភផ្នែកថវិការបស់អគ្គលេខាធិការដ្ឋាននៃកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ និងជំនួយមនុស្សធម៌ (DGD) និងជំនួយផ្នែកបច្ចេកទេសរបស់ការិយាល័យប្លេមីស៍សម្រាប់កិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ និងជំនួយការបច្ចេកទេស (VVOB)។

ឯកសារនេះក៏អាចទាញយកមកប្រើប្រាស់បានពីគេហទំព័រនេះ៖ www.telecentercambodia.org និង www.maff.gov.kh

**កំណត់សម្គាល់កម្មសិទ្ធិបញ្ញា**

រាល់ការបោះពុម្ពផ្សាយឯកសារត្រូវបានធ្វើឡើងដោយអនុលោមតាមអាជ្ញាប័ណ្ណ:
Creative Commons Attribution-Non Commercial-Share Alike 3.0 Unported License

លើកលែងតែឯកសារដែលមិនបានរាប់បញ្ចូល និងបញ្ជីរក្សាសិទ្ធខាងក្រោម។ មានន័យថា អ្នកអាចចែកចាយ ថតចម្លង ប្រែសម្រួល និងយកលំនាំតាមឯកសារនេះក្នុងន័យមិនរកកម្រៃដោយពុំចាំបាច់ស្នើសុំការអនុញ្ញាតជាមុនពីអ្នកបោះពុម្ពផ្សាយឡើយ តែប្រសិនបើអ្នកបង្កើត/កែប្រែថ្មី អ្នកត្រូវតែសុំអាជ្ញាប័ណ្ណពីម្ចាស់ដើមក្នុងល័ក្ខខ័ណ្ឌដូចគ្នាដែលបានបញ្ជាក់ខាងលើ ។

សម្រាប់ព័ត៌មានបន្ថែមអំពីអាជ្ញាប័ណ្ណខាងលើ សូមចូលទៅកាន់គេហទំព័រ
http://creativecommons.org/licenses/by-nc-sa/3.0/

**ឯកសារមិនរាប់បញ្ចូល និងរក្សាសិទ្ធិ**

ឯកសារមួយចំនួនក្នុងការបោះពុម្ពផ្សាយនេះមិនស្ថិតក្រោមអាជ្ញាប័ណ្ណខាងលើឡើយ។ ទាំងនេះគឺជាឯកសាររបស់ភាគីទី៣ ដែលត្រូវបានប្រើប្រាស់ដោយត្រឹមត្រូវ និងទទួលបានការអនុញ្ញាត។ អ្នកបោះពុម្ពផ្សាយមិនទទួលខុសត្រូវចំពោះល័ក្ខខ័ណ្ឌច្បាប់ណាមួយ (រួមបញ្ចូលទាំងការធ្វេសប្រហែស) ចំពោះការបាត់បង់ ឬខូចខាតដែលកើតមានឡើងដោយសារការប្រើប្រាស់ផ្នែកណាមួយនៃឯកសារដែលទទួលបានពីភាគីទី៣ឡើយ។

**ខ្លឹមសារនៃការបោះពុម្ពផ្សាយនេះមិនស្ថិតក្រោមការទទួលខុសត្រូវរបស់រដ្ឋាភិបាលប៊ែលហ្ស៊ិកឡើយ។**

# មាតិកា


**អារម្ភកថា** ........ II

**សេចក្តីថ្លែងអំណរគុណ** ........ IV

ACKNOWLEDGEMENT ........ V

**១. សេចក្តីផ្តើម** ........ ១

[illegible] ........ ១

[illegible] ........ ២

[illegible] ........ ៤

**១.៣ ការបញ្ច្រាបយេនឌ័រក្នុងសកម្មភាពចិញ្ចឹមជ្រូក** ........ ៦

**២. ការចិញ្ចឹមជ្រូកជាលក្ខណៈគ្រួសារ** ........ ៨

ជំពូក ១៖ សេចក្តីផ្តើមអំពីការចាប់ផ្តើវគ្គបណ្តុះបណ្តាល ........ ៨

ជំពូកទី ២៖ ការជ្រើសរើសពូជ ........ ១៨

ជំពូកទី ៣៖ ការសាងសង់ទ្រុង ........ ២៤

ជំពូកទី ៤៖ ចំណីជ្រូក ........ ២៩

ជំពូកទី ៥៖ ការថែទាំសុខភាពសត្វជ្រូក និងអនាម័យ ........ ៣៨

ជំពូកទី ៦៖ ជំងឺសំខាន់ៗរបស់ជ្រូក និងការព្យាបាល ........ ៤១

ជំពូកទី ៧៖ ការវិភាគសេដ្ឋកិច្ច ........ ៥៩

ជំពូកទី ៨៖ ផលប៉ះពាល់នៃការចិញ្ចឹមជ្រូកលើបរិស្ថាន ........ ៦៩

**ឯកសារយោង** ........ ៧១

# អារម្ភកថា

នៅក្នុងប្រទេសកម្ពុជា ជ្រូកត្រូវបានគេចិញ្ចឹមជាទូទៅសម្រាប់ទុកលក់ដើម្បីបង្កើនចំណូលគ្រួសារ ហើយយូរៗម្តង ទុកសម្រាប់ប្រើប្រាស់ក្នុងគ្រួសារ ជាពិសេសក្នុងពិធីមង្គលការ ឬបុណ្យទានផ្សេងៗ។ ការចិញ្ចឹមជ្រូក បានជួយឲ្យកសិករបង្កើនរបររកចំណូលគ្រួសារ ដោយពុំចាំបាច់ពឹងផ្អែកទាំងស្រុងលើផលិតកម្មស្រូវតែមួយមុខ។ ប្រព័ន្ធផលិតកម្មជ្រូកគេចែកជាការចិញ្ចឹមតាមទំលាប់(វិបុលវប្បកម្ម)ការចិញ្ចឹមពាក់កណ្តាលអតិផល និងការចិញ្ចឹមលក្ខណៈអតិផល (ទ្រង់ទ្រាយធំ)។ តែការចិញ្ចឹមជ្រូកភាគច្រើនរបស់កសិករកម្ពុជាគឺជាការចិញ្ចឹមតាមទំលាប់ដោយព្រលែងពាសវាលពាសកាល។ទាំងនេះគឺបណ្តាលមកពីប្រជាកសិករកម្ពុជានៅមានការខ្វះខាត ចំណេះដឹងបច្ចេកទេស និងជំនាញពីការចិញ្ចឹមជ្រូកប្រកបដោយអនាម័យ គុណភាព និងសុខភាពល្អ។

ដើម្បីចូលរួមដោះស្រាយនូវរាល់បញ្ហាខាងលើនេះឱ្យមានប្រសិទ្ធភាព និងឲ្យកាន់តែទទួលបានជោគជ័យអង្គការ **វីវីអូប៊ី** (VVOB = **សមាគមផ្លែមមីស៍ ដើម្បីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ និងជំនួយការបច្ចេកទេស**) ក្នុងកិច្ចសហការជាមួយនាយកដ្ឋានផ្សព្វផ្សាយកសិកម្ម (DAE) នៃអគ្គនាយកដ្ឋានកសិកម្ម (GDA) នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (MAFF) និងជាពិសេសមន្ទីរកសិកម្មខេត្តកណ្តាលបានរៀបចំចងក្រងសៀវភៅគោលការណ៍ណែនាំ សម្រាប់អ្នកសម្របសម្រួលវគ្គបណ្តុះបណ្តាលស្តីពី**ការចិញ្ចឹមជ្រូកជាលក្ខណៈគ្រួសារ** ក្នុងគោលបំណងដើម្បីចូលរួមបង្កើនចំណេះដឹង និងជំនាញដល់អ្នកសម្របសម្រួល ព្រមទាំងអ្នកពាក់ពន្ធ័ផ្សេងៗទៀត សម្រាប់ផ្ទេរនូវបច្ចេកទេសថ្មីៗដល់កសិករប្រកបដោយប្រសិទ្ធភាពខ្ពស់ សំដៅជម្រុញការចិញ្ចឹមជ្រូកជាលក្ខណៈគ្រួសារសម្រាប់គ្រួសារកសិករនៅកម្ពុជាឱ្យកាន់តែប្រសើរឡើង។ សៀវភៅនេះផ្តល់នូវគោលការណ៍ណែនាំយ៉ាងច្បាស់លាស់អំពីរបៀបផ្ទេរចំណេះដឹងបច្ចេកទេសអំពី **"ការចិញ្ចឹមជ្រូកជាលក្ខណៈគ្រួសារ"** ទៅកសិករតាមរយៈការប្រើប្រាស់គោលការណ៍សាលារៀនស្រែកសិករ។លើសពីនេះទៀតការយល់ដឹងពីយេនឌ័រនិងបរិស្ថានក៏ត្រូវបានគិតគូដាក់បញ្ចូលក្នុងគោលការណ៍ណែនាំនេះផងដែរក្នុងគោលបំណងលើកកម្ពស់ការយល់ដឹងពីការចូលរួមដោយស្មើភាពគ្នារវាងបុរស និងស្ត្រី ។ ចំណែកឯបរិស្ថានគឺផ្តោតទៅលើវិធីសាស្ត្រការចិញ្ចឹមជ្រូកតាមបែបធម្មជាតិ។

នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម (DAE) នៃអគ្គនាយកដ្ឋានកសិកម្ម (GDA) និងមន្ទីរកសិកម្មខេត្តកណ្តាលសូមសម្តែងនូវការដឹងគុណយ៉ាងជ្រាលជ្រៅបំផុត ចំពោះរដ្ឋាភិបាលប៊ែលហ្ស៊ិកតាមរយៈអង្គការ វីវីអូប៊ី (VVOB) ប្រចាំប្រទេសកម្ពុជាដែលបានសហការណ៍យ៉ាងជិតស្និទ្ធ ក្នុងការគាំទ្រទាំងថវិកា និងចូលរួមចំណែកយ៉ាងសកម្មក្នុងការរៀបរៀងចងក្រង ធ្វើតេស្តសាកល្បងកែសម្រួលសៀវភៅគោលការណ៍ណែនាំនេះឱ្យលេចចេញជារូបរាងឡើងពិតប្រាកដ។

នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម (DAE) នៃអគ្គនាយកដ្ឋានកសិកម្ម (GDA) មន្ទីរកសិកម្មខេត្តកណ្តាល និងអង្គការ វីវីអូប៊ី(VVOB) ប្រចាំប្រទេសកម្ពុជាសង្ឃឹមជឿជាក់យ៉ាងមុតមាំថាគោលការណ៍ណែនាំនេះនឹងជួយផ្តល់នូវទស្សនទានថ្មីៗរួមទាំងវិធីសាស្ត្រ សម្រាប់ការបណ្តុះបណ្តាលប្រកបដោយ

ប្រសិទ្ធភាពខ្ពស់សម្រាប់អ្នកសម្របសម្រួល និងដៃគូអនុវត្តផ្សេងៗទៀត ដែលកំពុងធ្វើការនៅក្នុងប្រទេសកម្ពុជាក្នុងការផ្ទេរនូវចំណេះដឹងដល់កសិករនិងដើម្បីចូលរួមជម្រុញលើកស្ទួយដល់ការចិញ្ចឹមជ្រូកជាលក្ខណៈគ្រួសារ។

រាជធានីភ្នំពេញ ថ្ងៃទី............... ខែ............... ឆ្នាំ២០១២

**អគ្គនាយកនៃអគ្គនាយកដ្ឋានកសិកម្ម**

**ស.-ខនឫទ្ធីគុណ**

# សេចក្តីថ្លែងអំណរគុណ

សៀវភៅគោលការណ៍ណែនាំសម្រាប់មន្ត្រីផ្សព្វផ្សាយនេះគឺជាផ្នែកមួយនៃបណ្តុំសៀវគោល ដែលត្រូវបានរៀបចំ ផលិតឡើង តាមរយៈកម្មវិធីធ្វើឱ្យប្រសើរឡើងនូវសេវាកម្មផ្សព្វផ្សាយកសិកម្ម ហៅកាត់ថាកម្មវិធីអ៊ីមេជ ចាប់តាំងពីឆ្នាំ ២០០៨ រហូតដល់ ឆ្នាំ២០១២នេះ។ កម្មវិធីអ៊ីមេជបានអនុវត្ត សកម្មភាពរបស់ខ្លួន ក្រោមការគ្រប់គ្រង និងណែនាំដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ជាពិសេសអគ្គនាយកដ្ឋានកសិកម្ម និងនាយកដ្ឋានផ្សព្វផ្សាយកសិកម្ម។ កម្មវិធីនេះត្រូវបានអនុវត្ត ដោយមន្ទីរកសិកម្មខេត្តកណ្តាលដោយមានការគាំទ្រ និងផ្តល់ជំនួយការបច្ចេកទេសពីអង្គការ វីវីអូប៊ី ប្រចាំប្រទេសកម្ពុជា។

សៀវភៅគោលការណ៍ណែនាំនេះលេចចេញជារូបរាងឡើង ដោយសារមានការជួយជ្រោមជ្រែងពីដៃគូពាក់ព័ន្ធទាំងឡាយតាមរយៈការធ្វើតេស្តសាកល្បង និងពិសោធន៍ជាគម្រូក្នុងដំណាក់កាលសាកល្បងមួយ និងជាពិសេសដោយសារតែមានក្រុមការងារបច្ចេកទេស ដែលរួមមានអ្នកជំនាញការពីថ្នាក់ជាតិ ខេត្ត និងស្រុកបានចូលរួមផ្តល់យោបល់កែលម្អយ៉ាងផុលផុស។ អង្គការវីវីអូប៊ីសូមសម្តែងនូវការគោរព និងដឹងគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទដែលបានខិតខំជួយជ្រោមជ្រែងក្នុងដំណើរការនៃការរៀបចំបង្កើតសៀវភៅគោលការណ៍ណែនាំនេះឡើង។ នេះជាការបង្ហាញឱ្យឃើញច្បាស់ថាវាបានកើតឡើង ដោយសារតែមានកិច្ចសហការយ៉ាងជិតស្និទ្ធរវាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទជាមួយនឹងអង្គការវីវីអូប៊ីតាមរយៈកម្មវិធីអ៊ីមេជ។

អង្គការវីវីអូប៊ីប្រចាំប្រទេសកម្ពុជាក៏សូមថ្លែងអំណរគុណផងដែរចំពោះរដ្ឋាភិបាលនៃសមាគមផ្លេមមីស៍ និងប្រទេសប៊ែលហ្ស៊ិច ដែលបានផ្តល់ជំនួយថវិកា សម្រាប់ការអនុវត្តកម្មវិធីអ៊ីមេជ។

ជាទីបញ្ចប់យើងខ្ញុំសូមជូនពរដល់មន្ត្រីផ្សព្វផ្សាយទាំងអស់ឱ្យបានទទួលជោគជ័យក្នុងការប្រើប្រាស់សៀវភៅគោលការណ៍ណែនាំនេះដើម្បីធ្វើឱ្យបច្ចេកទេសនៃការចិញ្ចឹមជ្រូកនៅក្នុងប្រទេសកម្ពុជាប្រសើរឡើង។

រាជធានីភ្នំពេញ ថ្ងៃទី..................ខែ..................ឆ្នាំ២០១២

V.V.O.B. vzw
Handelsstraat 31
B-1000 Brussel
FLEMISH ASSOCIATION FOR DEVELOPMENT COOPERATION AND TECHNICAL ASSISTANCE

Jan Geusens

ប្រធានគ្រប់គ្រងកម្មវិធី

នៃអង្គការវីវីអូប៊ីប្រចាំប្រទេសកម្ពុជា

# Acknowledgement

This manual for extension workers is part of a series of manuals that were developed during the Improving Agricultural Extension (ImAgE) programme that ran from 2008 to 2012. The programme was implemented under the supervision and guidance of the Ministry of Agriculture, Forestry and Fisheries, in particular the General Directorate of Agriculture and its Department of Agricultural Extension. The implementation was done by the Provincial Department of Agriculture of Kandal with the support and technical assistance of VVOB Cambodia.

This manual came into existence with the help of all partners involved after a period of try-outs and piloting. In particular the quality assurance working group consisting of experts at national, provincial and district level contributed greatly. VVOB Cambodia would like to express its sincere gratitude and deepest respect to Ministry of Agriculture, Forestry and Fisheries for its strong commitment during this process. The manual is a clear evidence of the close cooperation between MAFF and VVOB throughout the programme.

VVOB Cambodia would also like to thank the Belgian and Flemish governments for providing the funding for the implementation of the ImAgE programme.

We wish the extension workers success in the use of this training manual for the improvement of pig's production throughout Cambodia.

Phnom Penh, July 2012,

Jan Geusens
Programme Manager
VVOB Cambodia

# ១. សេចក្តីផ្តើម

### ១.១ [illegible]

ប្រទេសកម្ពុជាគឺជាប្រទេសកសិកម្មដែលមានប្រជាជនប្រមាណ៨០%ប្រកបរបរកសិកម្ម។ បន្ទាប់ពីដំណាំស្រូវវិស័យចិញ្ចឹមសត្វជាប្រភពចំណូលដ៏សំខាន់សម្រាប់កសិករខ្មែរ។ ប្រជាជនកម្ពុជាប្រមាណ៧០% និយមចូលចិត្តចិញ្ចឹមជ្រូក ដើម្បីបង្កើនសន្តិសុខស្បៀង ប្រាក់ចំណូលគ្រួសារ និងលាមកអាចយកទៅប្រើសម្រាប់ដាក់ឡជីវឧស្ម័ន និងជីសម្រាប់ដាក់ដំណាំផ្សេងៗធ្វើឱ្យជីវភាពរស់នៅប្រចាំថ្ងៃរបស់ពួកគាត់មានភាពល្អប្រសើរឡើង។



ជាទូទៅការចិញ្ចឹមជ្រូករបស់ប្រជាកសិករនៅជនបទគឺធ្វើទៅតាមទម្លាប់ប្រពៃណី ហើយការយល់ដឹងអំពីបច្ចេកទេសចិញ្ចឹមជ្រូកនូវមានកម្រិត ជាហេតុធ្វើឱ្យប្រជាកសិករជួបនូវការលំបាកក្នុងការចិញ្ចឹមជ្រូក។ ដើម្បីជម្រុញវិស័យចិញ្ចឹមជ្រូកឲ្យកាន់តែល្អប្រសើរ ដូចនេះប្រជាកសិករចាំបាច់ត្រូវយល់ដឹងអំពីបច្ចេកទេស ចំណេះដឹង ជំនាញ និងបទពិសោធន៍ថ្មីៗបន្ថែមទៀត ដើម្បីជម្រុញបរិមាណ និងគុណភាពផលិតកម្មឲ្យបានខ្ពស់ បំពេញតម្រូវការទីផ្សារ ដោយស្របទៅតាមកំណើនប្រជាជនបច្ចុប្បន្ន។ ដូចនេះកសិករដែលចាប់អារម្មណ៍ ឬមានបំណងក្នុងការចិញ្ចឹមជ្រូកត្រូវចូលរួមក្នុងវគ្គបណ្តុះបណ្តាលលើជំនាញគ្រប់គ្រង និងបច្ចេកទេសចិញ្ចឹមដូចជាការធ្វើផែនការផលិតកម្ម ការធ្វើវិភាគសេដ្ឋកិច្ច ការសង់ទ្រុង ការជ្រើសរើសពូជ ការកែលម្អរចំណី ការតាមដានសុខភាព និងការចាក់វ៉ាក់សាំងការពារជម្ងឺ។ បន្ថែមពីលើនេះប្រជាកសិករក៏ចាំបាច់ត្រូវយល់ដឹងផងដែរពីការចំណាយធនធាន និងកំលាំងពលកម្មមុនពេលសម្រេចចិត្តចិញ្ចឹមជ្រូក។

□□□□□□□□□□□□□□□□□□□□□□□

អង្គការ "វីវីអូប៊ី" (VVOB) មកពីពាក្យពេញថា **សមាគមផ្លែមមីស៍ដើម្បីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ និងជំនួយការបច្ចេកទេស)** គឺជាអង្គការមួយដែលមិនរកប្រាក់កម្រៃ ដែលត្រូវបានបង្កើតឡើងនៅក្នុងឆ្នាំ១៩៨២ ក្រោមការឧបត្ថម្ភថវិកាពីរដ្ឋាភិបាលសហព័ន្ធនៃប្រទេសប៊ែលហ្ស៊ិក។

ដោយមានកិច្ចសហការជាមួយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ (កសក) នៃប្រទេសកម្ពុជា និងនាយកដ្ឋានផ្សព្វផ្សាយកសិកម្ម (នផ្សក) បច្ចុប្បន្ន "វីវីអូប៊ី" កំពុងអនុវត្តកម្មវិធីមួយ (កម្មវិធី "**អ៊ីមេដ**") ក្នុងគោលបំណងធ្វើឱ្យប្រសើរឡើងសេវាកម្មផ្សព្វផ្សាយកសិកម្មនៅថ្នាក់ខេត្ត និងថ្នាក់ស្រុកតាមរយៈការអភិវឌ្ឍសមត្ថភាពរបស់មន្ត្រីផ្សព្វផ្សាយ។ កម្មវិធីនេះបានធ្វើការសាកល្បងនៅក្នុងខេត្តកណ្តាលដោយសហការយ៉ាងជិតស្និទ្ធជាមួយមន្ទីរកសិកម្មខេត្ត។

ក្នុងចំណោមគោលបំណងសំខាន់ៗរបស់កម្មវិធីគឺមានគោលបំណងមួយផ្តោតលើការផលិតសៀវភៅគោលការណ៍ណែនាំអំពីបច្ចេកទេស និងវិធីសាស្ត្រផ្សព្វផ្សាយសិកម្ម ព្រមទាំងសៀវភៅណែនាំអំពីការគ្រប់គ្រងសម្រាប់ឱ្យមន្ត្រីផ្សព្វផ្សាយខេត្ត និងមន្ត្រីកសិកម្មស្រុកយកទៅប្រើប្រាស់ក្នុងការងាររបស់ខ្លួន។ រាល់សៀវភៅណែនាំទាំងអស់ត្រូវបានបង្កើតឡើងតាមរយៈយន្តការ "ក្រុមកាងារ" ដែលមានការចូលរួមពីមន្ត្រីជំនាញមកពីនាយកដ្ឋានផលិតកម្ម និងបសុព្យាបាល នាយកដ្ឋានផ្សព្វផ្សាយកសិកម្មរហូតដល់មន្ត្រីផ្សព្វផ្សាយកសិកម្មថ្នាក់ស្រុក ដើម្បីផលិតសៀវភៅគោលស្តីអំពីការកែលម្អវិធីសាស្ត្រចិញ្ចឹមជ្រូកជាលក្ខណៈគ្រួសារនេះ។

សមាជិកក្នុងក្រុមការងារបង្កើតសៀវភៅណែនាំអំពី**ការកែលម្អបច្ចេកទេសចិញ្ចឹមជ្រូកជាលក្ខណៈ គ្រួសារនេះ**" មានដូចខាងក្រោម:

- លោកស្រី **អុក សាវីន** អនុប្រធាននាយកដ្ឋានផលិតកម្ម និងបសុព្យាបាលនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
- លោក **ទី គៀខ** តំណាងមកពីនាយកដ្ឋានផ្សព្វផ្សាយកសិកម្មនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
- លោក **មុត សាវ៉ាត** មន្ត្រីផ្សព្វផ្សាយកសិកម្មខេត្ត ប្រចាំស្រុកគៀនស្វាយ
- លោក **គិម រិន** មន្ត្រីផ្សព្វផ្សាយកសិកម្មខេត្ត ប្រចាំស្រុកកណ្តាលស្ទឹង
- លោក **មី ហុងគ្រឿន** មន្ត្រីផ្សព្វផ្សាយកសិកម្មស្រុកពញាឮ

ក្រុមការងារផលិតសៀវភៅគោលការណ៍ណែនាំបច្ចេកទេសចិញ្ចឹមជ្រូកនេះត្រូវបានដឹកនាំ និងសម្របសម្រួលដោយមន្ត្រីបច្ចេកទេសនៃកម្មវិធី "**អ៊ីមេដ**"។ សមាជិកក្រុមការងារបានចូលរួមផ្តល់ជាព័ត៌មាន បទពិសោធន៍ និងចំណេះដឹងនៅក្នុងដំណើរការពិភាក្សា។ សមាជិកក្រុមការងារបានជួបប្រជុំគ្នាចំនួនច្រើនដង ដើម្បីពិភាក្សាគ្នាក្នុងការផលិតសៀវភៅនេះ។

រូបភាពគូរដោយលោក **ឆា សាខុឆ** វិចិត្រករប្រចាំនាយកដ្ឋានផ្សព្វផ្សាយកសិកម្ម។ គណៈកម្មាធិការត្រួតពិនិត្យ កែសម្រួល និងវាយតម្លៃមាន:

- លោក **ម៉ាក់ សឿន** ប្រធាននាយកដ្ឋានផ្សព្វផ្សាយកសិកម្ម
- លោកស្រី **អ៊ុក សាវីន** អនុប្រធាននាយកដ្ឋានផលិតកម្ម និងបសុព្យាបាលនៃក្រសួង កសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
- លោក **ទី គៀង** តំណាងមកពីនាយកដ្ឋានផ្សព្វផ្សាយកសិកម្មនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
- លោកស្រី **ពៅ វណ្ណី** អនុប្រធានការិយាល័យអភិវឌ្ឍធនធានមនុស្សនៃនាយកដ្ឋាន ផ្សព្វផ្សាយកសិកម្ម
- លោក **យន់ សុផាន** អនុប្រធានការិយាល័យប្រព័ន្ធកសិកម្មនៃនាយកដ្ឋាន ផ្សព្វផ្សាយកសិកម្ម
- លោកស្រី **ចែម រដ្ឋា** មន្ត្រីជំនាញផ្នែកផលិតកម្ម និងបសុព្យាបាល ខេត្តកណ្តាល
- លោក **គីម រិន** មន្ត្រីផ្សព្វផ្សាយកសិកម្មខេត្ត ប្រចាំស្រុកកណ្តាលស្ទឹង
- លោក **ជាប វន្ថា** មន្ត្រីផ្សព្វផ្សាយកសិកម្ម ស្រុកកណ្តាលស្ទឹង

## ១.២ □□□□□□□□ □□□□□□□□□□□□□□

គោលបំណងរបស់សៀវភៅគោលការណ៍ណែនាំនេះ គឺដើម្បីជួយណែនាំដល់មន្ត្រីផ្សព្វផ្សាយក្នុងការបណ្តុះបណ្តាល និងគាំទ្រដល់ប្រជាកសិករ ក្នុងការចិញ្ចឹមជ្រូកជាលក្ខណៈគ្រួសារ។ វាជាសៀវភៅគោលសម្រាប់ការបណ្តុះបណ្តាលដែលផ្តល់នូវពត៌មានជាមូលដ្ឋានគ្រឹះអំពីវិធីសាស្ត្រសាលារៀនស្រែកសិក។វាពន្យល់ប្រាប់ដល់មន្ត្រីផ្សព្វផ្សាយនូវសកម្មភាពជាជំហានៗដែលត្រូវធ្វើជាមួយកសិករ។

គោលបំណងសំខាន់ៗនៃសៀវភៅគោលនេះគឺ:

គោលបំណងជាក់លាក់នៃការបង្កើតសៀវភៅគោលនេះគឺ:

- ផ្តល់ជាចំណេះដឹងស្របទៅតាមស្ថានភាពជាក់ស្តែងស្របតាមទីកន្លែង និងក្រុមគោលដៅទាក់ទងនឹងការកែលម្អបច្ចេកទេសចិញ្ចឹមជ្រូកជាលក្ខណៈគ្រួសារ (សម្រាប់មន្ត្រីផ្សព្វផ្សាយកសិកម្ម)
- ផ្តល់ការណែនាំដល់មន្ត្រីផ្សព្វផ្សាយកសិកម្មនូវវិធីសាស្ត្រក្នុងការបណ្តុះបណ្តាលកសិករអំពីបច្ចេកទេសចិញ្ចឹមជ្រូកជាលក្ខណៈគ្រួសារ
- ដើម្បីជំរុញឱ្យកសិករចាប់ផ្តើមអនុវត្តបច្ចេកទេសនេះ
- ដើម្បីធ្វើឱ្យប្រសើរឡើងនូវស្ថានភាពប្រាក់ចំណូលរបស់កសិករតាមរយៈការកែលម្អប្រសិទ្ធភាពផលិតកម្ម

ក្រុមគោលដៅសម្រាប់សៀវភៅគោលនេះគឺមន្ត្រីផ្សព្វផ្សាយថ្នាក់ស្រុកនិងខេត្ត។ ក្រៅពីក្រុមគោលដៅទាំងនេះមន្ទីរកសិកម្មខេត្ត អង្គការក្រៅរដ្ឋាភិបាល និងដៃគូអនុវត្តកសិកម្មផ្សេងៗទៀតក៏អាចប្រើសៀវភៅគោលការណ៍ណែនាំនេះបានផងដែរ។ វាត្រូវបានរៀបរៀងឡើងដោយប្រើភាសាមានលក្ខណៈច្បាស់ សាមញ្ញ និងងាយយល់ដែលសាកសមទៅនឹងសមត្ថភាពរបស់មន្ត្រីផ្សព្វផ្សាយ។ គ្រប់ជំពូកគឺមានលំនាំ ទម្រង់ដូចខាងក្រោម:

១. <u>រយៈពេល:</u> ប៉ាន់ប្រមាណអំពីពេលវេលាចាំបាច់សម្រាប់វគ្គបណ្តុះបណ្តាលឬការប្រជុំឬសកម្មភាព

២. <u>គោលបំណង:</u> ពន្យល់ពីគោលបំណងរបស់វគ្គ/ការប្រជុំ/សកម្មភាព និងរៀបរាប់ប្រាប់ពីអ្វី ដែលកសិករទទួលយកបានជាចំណេះក្រោយវគ្គចប់

៣. <u>សម្ភារៈ</u> បង្ហាញពីសម្ភារៈចាំបាច់សម្រាប់វគ្គបណ្តុះបណ្តាល/ការប្រជុំ/សកម្មភាព

៤. <u>ដំណើរការ:</u> រៀបរាប់ពីសកម្មភាពខុសៗគ្នាដែលអ្នកនឹងត្រូវធ្វើក្នុងវគ្គ ឬការប្រជុំឬសកម្មភាព

៥. <u>ឧបសម្ព័ន្ធ:</u> ជំពូកខ្លះមានភ្ជាប់ឧបសម្ព័ន្ធដើម្បីបង្ហាញនូវពត៌មានបន្ថែម ឧទាហរណ៍ រូបភាព ករណីសិក្សា



រូបសញ្ញានេះ មានន័យថាអ្នកត្រូវអានពត៌មានជំនួយបន្ថែមទៀត !

<u>សំខាន់:</u>

បញ្ហាបរិស្ថាន និងយេនឌ័រក៏ត្រូវបានបញ្ជ្រាបបញ្ចូលនៅក្នុងសៀវភៅគោលការណ៍ណែនាំនេះផងដែរ។

<u>សំគាល់:</u>

អមជាមួយនិងសៀវភៅគោលការណ៍ណែនាំនេះក៏មានកូនសៀវភៅបច្ចេកទេសមួយទៀតផងដែរ ដែលអាចចែកជូនដល់កសិករ និងមន្ត្រីផ្សព្វផ្សាយជាជំនួយបន្ថែមទៀត។

កំណត់សំគាល់:

សៀវភៅណែនាំនេះត្រូវយកទៅប្រើប្រាស់អមជាមួយសៀវភៅបច្ចេកទេស ដើម្បីផ្តល់ឱ្យមន្ត្រីផ្សព្វផ្សាយកសិកម្មនូវចំណេះដឹងកាន់តែលម្អិត និង<u>ខិតប័ណ្ណបច្ចេកទេស</u>សម្រាប់ផ្តល់ជូនដល់កសិករ។

*សៀវគោលនេះពុំមានរក្សាសិទ្ធិហាមឃាត់ការបោះពុម្ពផ្សាយឡើងវិញនោះទេ ដូច្នេះផ្នែកខ្លះឬទាំងស្រុងនៃសៀវភៅនេះអាចត្រូវបានផលិតឡើងវិញដោយពុំចាំបាច់សុំការអនុញ្ញាតិពីអង្គការវីអូប៊ី ឬពីនាយកដ្ឋានផ្សព្វផ្សាយកសិកម្មនោះទេ តែទោះជាយ៉ាណាក៏ដោយប្រភពត្រូវតែទទួលស្គាល់។*

## ១.៣ ការបញ្ជាបយេនឌ័រក្នុងសកម្មភាពចិញ្ចឹមជ្រូក

វាជាការពិតដែលបុរសនិងស្ត្រីមានតួនាទីចរិកលក្ខណៈយេនឌ័រខុសគ្នាអាស្រ័យលើសង្គមរស់នៅជាអ្នកឱ្យតម្លៃ។ បុរស និងស្ត្រីមានតំរូវការ ការរំពឹងទុក ឱកាស និងបញ្ហាប្រឈមផ្សេងៗគ្នាដែលកំណត់នូវ ចរិកលក្ខណៈរបស់ពួកគេ។ ក្នុងគម្រោងអភិវឌ្ឍន៍ដូចជាកម្មវិធីអ៊ីមេជដែលមានគោលដៅធ្វើឱ្យបុរសនិងស្ត្រី ទទួលបានផលប្រយោជន៍ស្មើគ្នាពីសកម្មភាពរបស់កម្មវិធី គឺចាំបាច់ត្រូវតែដឹងពីតំរូវការនិងការចង់បាន របស់ បុរសនិងស្ត្រី ដើម្បីធ្វើយ៉ាងណាឱ្យប្រាកដថាសកម្មភាពរបស់គម្រោងគឺពិតជាបានឆ្លើយតបទៅនឹងសេចក្តីត្រូវ សម្រាប់ទាំងបុរសនិងស្ត្រី។ យើងចាំបាច់ត្រូវស្វែងយល់ផងដែរ អំពី នរណាត្រូវធ្វើអ្វី ហើយត្រូវមានធនធាន អ្វីខ្លះ ដើម្បីឱ្យយើងអាចផ្តល់វគ្គបណ្តុះបណ្តាលឱ្យចំគោលដៅសម្រាប់អ្នកដែលត្រូវអនុវត្តស្វែងរកនូវគម្លាតនៃការគ្រប់គ្រងនិងប្រើប្រាស់ធនធាន ហើយធ្វើយ៉ាងណាជម្រុញឱ្យបុរសនិងស្ត្រីមានការចូលរួមប្រកបដោយសមភាព។

*<u>ស្ថានភាពរបស់ស្ត្រីជនបទក្នុងប្រទេសកម្ពុជា</u>*

- ស្ត្រីនៅជនបទជាច្រើន គឺត្រូវនៅផ្ទះដើម្បីមើលថែគ្រួសារ និង ធ្វើការងារផ្ទះ
- ជាទូទៅស្ត្រីទាំងនោះមិនសូវចេះអក្សរ ដែលធ្វើឱ្យពួកគាត់ពិបាកក្នុងការរកបានការងារល្អៗ
- ស្ត្រីខ្មែរនៅជនបទចូលចិត្តប្រកបមុខរបរនៅក្នុងភូមិ-ស្រុករបស់ពួកគាត់នៅជិតផ្ទះនិងក្រុមគ្រួសារ
- ពួកគាត់មានភាពឧស្សាហ៍ព្យាយាម និងមានទេពកោសល្យក្នុងការងារកសិកម្មជាពិសេសការដាំដុះ និងចិញ្ចឹមសត្វ
- ពួកគាត់មិនសូវមានមុខមាត់នៅក្នុងសង្គមឡើយដោយសារតែពួកគាត់ភាគច្រើនធ្វើការងារមិនមានកម្រៃ និងសិទ្ធិអំណាចក្នុងការធ្វើសេចក្តីសម្រេចចិត្តទាំងនៅក្នុងគ្រួសារនិងសង្គម
- ភាគច្រើនពួកគាត់រស់នៅក្រោមការគ្រប់គ្រងរបស់ស្វាមី និងមានឱកាសចូលរួមការងារអភិវឌ្ឍប៉ុន្តែពុំសូវមានសិទ្ធិសម្រេច

<u>សារៈសំខាន់នៃការចិញ្ចឹមជ្រូកលក្ខណៈគ្រួសារក្នុងការលើកកំពស់ជីវភាពរបស់ស្ត្រីនៅជនបទ</u>

- វាជាការងារសមស្របសម្រាប់ស្ត្រីមានតួនាទីបំពេញការងារនៅក្បែរផ្ទះបន្ទាប់ពីការងារដាំដុះ និងការងារផ្ទះ
- វាមានភាពងាយស្រួលក្នុងការគ្រប់គ្រងថែទាំ
- ចំណាយទុនតិច ឆាប់បាទទួលផលបើប្រៀបធៀបទៅនឹងការចិញ្ចឹមសត្វដទៃទៀត
- វាជាប្រភពចំណូលមួយសម្រាប់ស្ត្រី ដែលអាចឱ្យពួកគាត់មានលទ្ធភាពផ្គត់ផ្គង់គ្រួសារ និងលើកកម្ពស់ជីវភាពគ្រួសារ និងចូលរួមចំណែកកាត់បន្ថយភាពក្រីក្រ និងមានឱកាសធ្វើសេចក្តីសម្រេចចិត្ត
- គាត់អាចរកបានវត្ថុធាតុដើមដែលមាននៅក្នុងភូមិ ដោយមិនចាំបាច់ធ្វើដំណើរទៅឆ្ងាយពីលំនៅឋាន

- ផ្គត់ផ្គង់ម្ហូបអាហារប្រកបដោយគុណភាព និងសុវត្ថិភាពសម្រាប់គ្រួសារ និងអាចកាត់បន្ថយការចំណាយលើម្ហូបអាហារបានមួយចំនួន
- ទាំងបុរស និងស្ត្រីមានតួនាទីដូចគ្នាក្នុងការងារចិញ្ចឹមជ្រូកដែលវានឹងផ្តល់ពួកគេនូវឱកាសធ្វើផែនការ និងអនុវត្តការងារជាមួយគ្នាដើម្បីធ្វើឱ្យប្រសើរឡើងនូវទំនាក់ទំនង និងការរួមគ្នាធ្វើសេចក្តីសម្រេចចិត្ត

<u>ការបញ្ជ្រាបយេនឌ័រៈ</u>

ការបញ្ជ្រាបយេនឌ័រគឺជាការបញ្ចូលនូវកិច្ចអន្តរាគមន៍ចផ្នែកយេនឌ័រ ទៅក្នុងសកម្មភាពទាំងលាយដែលយើងធ្វើ។ ការបញ្ជ្រាបយេនឌ័រក្នុងសកម្មភាពចិញ្ចឹមជ្រូក មានន័យថាជាការបញ្ចូលនូវបញ្ហាយេនឌ័រពាក់ព័ន្ធទៅក្នុងគ្រប់ដំណាក់កាលនៃការចិញ្ចឹមជ្រូក។

ជំនួយស្មារតីសំខាន់ៗ សម្រាប់មន្ត្រីផ្សព្វផ្សាយ ក្នុងការបញ្ជ្រាបយេនឌ័រតាមរយៈសៀវភៅណែនាំនេះ៖

- ការកំណត់តួនាទីយេនឌ័រ និង ឧបសគ្គដែលបុរស និង ស្ត្រី ត្រូវប្រឈមនៅក្នុងការងារចិញ្ចឹមជ្រូក
- ការអញ្ជើញបុគ្គលដែលទទួលខុសត្រូវតាមការងារនីមួយៗដើម្បីចូលរួមការបណ្តុះបណ្តាល
- ការផ្តោតការយកចិត្តទុកដាក់ទៅលើស្ត្រី ពីព្រោះពួកគាត់ភាគច្រើនគឺជាអ្នកទទួលខុសត្រូវក្នុងការចិញ្ចឹមមាន់ក៏ប៉ុន្តែគេមិនត្រូវបដិសេដបុរសនោះដែរប្រសិនបើបុរសបានចូលរួមនៅក្នុងការងារគ្រួសារ
- រៀបចំយុទ្ធសាស្ត្រដើម្បីបំបាត់ចោលនូវឧបសគ្គដែលរារាំងដល់ការចូលរួមរបស់បុរស និងស្ត្រី
- លើកទឹកចិត្តទាំងបុរស និងស្ត្រីឱ្យហ៊ាននិយាយ និងចេះគោរពមតិយោបល់គ្នា
- បង្ហាញអំពីតួនាទីរបស់ពួកគាត់នៅក្នុងការធ្វើសេចក្តីសម្រេចចិត្ត និងភាពជាអ្នកដឹកនាំជាពិសេសតួនាទីរបស់ស្ត្រី
- ការកំណត់ពេលវេលានិងទីកន្លែងដែលសមស្របសម្រាប់អ្នកចូលរួមជាពិសេសសម្រាប់ស្ត្រី
- ពិភាក្សាអំពីមធ្យោបាយដែលសមស្របបំផុតក្នុងការបែងចែកអត្ថប្រយោជន៍ដែលបានពីការចិញ្ចឹមជ្រូក
- ការបង្កើតសម្ភារៈផ្សព្វផ្សាយមួយចំនួនដែលអាចឱ្យស្ត្រីដែលមិនសូវចេះអក្សរប្រើប្រាស់បាន
- តាមដានត្រួតពិនិត្យមើលអន្តរាគមន៍ និងវិសមភាពតាមរយៈការប្រមូលទិន្នន័យបែងចែកភេទ (dissagregate data)

លទ្ធផលដែលបង្កើតឱ្យមាននូវអន្តរាគមន៍ទាំងនេះ គឺមិនមែនគ្រាន់តែផ្តល់សិទ្ធិអំណាចដល់ស្ត្រីដែលជាផលិតករប៉ុណ្ណោះទេក៏ប៉ុន្តែវាក៏បានជួយជម្រុញឱ្យពួកគាត់កាន់តែមានមុខមាត់នៅក្នុងគ្រួសារ និងសង្គមនៅពេលដែលស្ត្រីកាន់តែមានលទ្ធភាពរកប្រាក់ចំណូល និងមានសិទ្ធិក្នុងការធ្វើសេចក្តីសម្រេចចិត្ត។

## ២. ការចិញ្ចឹមជ្រូកជាលក្ខណៈគ្រួសារ

### ជំពូក ១៖ សេចក្តីផ្តើមអំពីការចាប់ផ្តើមវគ្គបណ្តុះបណ្តាល

<u>រយៈពេល:</u> ៤ម៉ោង

<u>គោលបំណង:</u>

- ដើម្បីឱ្យកសិករយល់ដឹងពីអត្ថប្រយោជន៍នៃការចិញ្ចឹមជ្រូកជាលក្ខណៈគ្រួសារបានល្អប្រសើរ
- ដើម្បីឲ្យកសិករយល់ពីវិធីសាស្រ្តសាលារៀនស្រែកសិករអំពីការចិញ្ចឹមជ្រូក
- ជ្រើសរើសកសិករដែលមានការចាប់អារម្មណ៍ ជម្រុញ និងលើកទឹកចិត្តឱ្យចូលរួមវគ្គបណ្តុះបណ្តាល
- ដើម្បីអភិវឌ្ឍចំណេះដឹង បទពិសោធន៍ ក៏ដូចជាការបំពេញបន្ថែមលើការងារចិញ្ចឹមជ្រូកជាលក្ខណៈគ្រួសារ
- បង្កើតផែនការសកម្មភាពសម្រាប់វគ្គបណ្តុះបណ្តាលបន្ទាប់

<u>សម្ភារ:</u>
ក្រដាស់ផ្ទាំងធំ ហ្វឺត ស្កុត សៀវភៅកត់ត្រា ប៊ិច ក្រដាស A4 និង ឧបសម្ព័ន្ធ ១, ២ និង៣

<u>ដំណើរការ</u>

សកម្មភាព ១៖ ការណែនាំខ្លួនរបស់កសិករ និងអ្នកសម្របសម្រួល

១. ឱ្យកសិករណែនាំខ្លួន ដោយប្រាប់ពីឈ្មោះ ស្ថានភាពគ្រួសារ និងទីកន្លែងដែលពួកគាត់រស់នៅ (អ្នកសម្របសម្រួលក៏ត្រូវណែនាំខ្លួនផងដែរ)

២. ប្រាប់ពីគោលបំណងរបស់វគ្គបណ្តុះបណ្តាល

សកម្មភាព ២៖ ការចែករំលែកបទពិសោធន៍

១. បែងចែកកសិករជាក្រុមតូច (ឧ. ឱ្យពួកគាត់រាប់លេខពី១-២-៣ ដើម្បីចែកក្រុម) ហើយប្រាប់គាត់រើសប្រធានក្រុម អ្នកកត់ត្រា និងអ្នកឡើងបង្ហាញ

២. ឱ្យក្រុមនីមួយៗពិភាក្សាសំណួរទាំងនេះ
   - តើពួកគាត់ចិញ្ចឹមជ្រូកប៉ុន្មានក្បាល?
   - តើពួកគាត់ចិញ្ចឹមជ្រូកមានទ្រុងដែរឬទេ?
   - តើពួកគាត់ឱ្យជ្រូកស៊ីចំណីអ្វីខ្លះ?
   - តើពួគាត់ជួបប្រទះបញ្ហាប្រឈមអ្វីខ្លះ?
   - តើមានដំណោះស្រាយអ្វីខ្លះពេលមានបញ្ហាកើតឡើង?

៣. ប្រាប់អ្នកកត់ត្រាឱ្យសរសេរចំលើយទាំងអស់លើក្រដាសផ្ទាំងធំ និងក្នុងសៀវភៅកត់ត្រារបស់គាត់

៤. ឱ្យក្រុមនីមួយៗឡើងបង្ហាញលទ្ធផលរបស់ខ្លួន ហើយបំផុសឱ្យកសិករដ៏ទៃទៀតសួរសំណួរ

៥. កត់ត្រាលើក្រដាស់ផ្ទាំងធំនូវបទពិសោធន៍ចិញ្ចឹមជ្រូករបស់កសិករម្នាក់ៗហើយធ្វើការបូកសរុប

សកម្មភាព ៣៖ ការចិញ្ចឹមជ្រូកជាលក្ខណៈគ្រួសារ

១. សរសេរពាក្យ **ការចិញ្ចឹមជ្រូកជាលក្ខណៈគ្រួសារ** ដាក់លើផ្ទាំងក្រដាស់ធំ

២. សួរកសិករថា តើ**ការចិញ្ចឹមជ្រូកជាលក្ខណៈគ្រួសារ** មានន័យដូចម្តេច?

៣. សរសេរចំលើយរបស់គាត់ដាក់លើផ្ទាំងក្រដាស់ធំ

៤. ពន្យល់ប្រាប់កសិករអំពី "**ការចិញ្ចមជ្រូកជាលក្ខណៈគ្រួសារ**" ដោយប្រើជំនួយស្មារតីខាងក្រោម

៥. ប្រាប់កសិករថា ការចិញ្ចឹមជ្រូកជាលក្ខណៈគ្រួសារអាចធ្វើក្នុងទ្រង់ទ្រាយតូច ឬមធ្យម

**ជំនួយស្មារតី: លក្ខណៈពិសេសនៃការចិញ្ចឹមជ្រូកជាលក្ខណៈគ្រួសារ**

- ជ្រូកចិញ្ចឹមក្នុងទ្រុងប្រកបដោយអនាម័យល្អត្រឹមត្រូវ
- ទ្រុងជ្រូកនៅក្បែរលំនៅដ្ឋាន
- ការជ្រើសរើសពូជ
- ប្រើចំណីកាកសំណល់ផ្ទះបាយ និងបន្លែបៃតងឱ្យជ្រូកស៊ី ហើយមិនចំណាយច្រើន
- ការថែទាំ
- វិធានការការពារ អនាម័យ និងជីវសុវត្ថិភាព
- ធានាសុខភាពសត្វ សុខភាពសាធារណៈ និង បរិស្ថាន។ល។

**ជំនួយស្មារតីៈ តើចំណីបៃតងជាអ្វី?**

ចំណីបៃតងគឺជាប្រភេទរុក្ខជាតិផ្សេងៗដែលអាចរកបាននៅជុំវិញលំនៅដ្ឋានមានដូចជាៈ ចកបាយទា ផ្ទីរ ដើមចេក ស្លឹកកន្ទុំថេត ត្រកួន ស្លឹកដំឡូងមី ស្លឹកអង្គាដី ។ល។...មកផ្សំដើម្បីធ្វើជាចំណីជ្រូក។

សកម្មភាព ៤ៈ ការរំពឹងទុក គោលបំណង និងដំណើរការវគ្គបណ្តុះបណ្តាល

១. ឱ្យកសិករសរសេរនូវការរំពឹងទុកពីវគ្គបណ្តុះបណ្តាល

២. ឱ្យកសិករអានចំលើយរបស់គាត់ម្នាក់ម្តងៗ

៣. សរសេរចំលើយទាំងនោះដាក់លើផ្ទាំងក្រដាស់ធំ ហើយពិភាក្សាជាមួយកសិករ

៤. កំណត់គោលបំណងសម្រាប់វគ្គបណ្តាលបណ្តាលនេះ ដោយប្រើជំនួយស្មារតីខាងក្រោម

៥. សួរកសិករថាតើជម្រើសនិងអត្ថប្រយោជន៍ណាមួយដែលទទួលបានពីការចិញ្ចឹមជ្រូក ហើយប្រៀបធៀបជាមួយនិងចំលើយក្នុងប្រអប់ខាងក្រោម

**គោលបំណងនៃវគ្គបណ្តុះបណ្តាលៈ**

- ដើម្បីទទួលបានចំណេះដឹងនិងបទពិសោធន៍ក្នុងការចិញ្ចឹមជ្រូកដែលជាវិភាគទានចូលរួមបង្កើនប្រាក់ចំណូលក្នុងគ្រួសារនៅជនបទ
- ស្វែងយល់ពីបញ្ហាយេនឌ័រនៅក្នុងសកម្មភាពចិញ្ចឹមជ្រូក

**ជំរើសផ្សេងៗក្នុងការចិញ្ចឹមជ្រូកជាលក្ខណៈគ្រួសារៈ**

- *ចិញ្ចឹមយកសាច់ៈ*
  កសិករនិយមចូលចិត្តចិញ្ចឹមជ្រូកយកសាច់ ដើម្បីលក់យកប្រាក់ក្នុងការបង្កើនជីវភាពគ្រួសារ។
- *ចិញ្ចឹមទុកពូជ*
  កសិករមួយចំនួនទៀតនិយមចូលចិត្តចិញ្ចឹមជ្រូកពូជ ដើម្បីយកកូនលក់។ ជ្រូកមេ១ក្បាលអាចបង្កើតកូនម្តងជាមធ្យមបានពី៦-៧ក្បាល

**អត្ថប្រយោជន៍នៃការចិញ្ចឹមជ្រូកជាលក្ខណៈគ្រួសារៈ**

- ងាយស្រួលឱ្យចំណី និងទឹកដល់ជ្រូក
- ងាយស្រួលថែទាំ និងតាមដានសុខភាព
- ងាយស្រួលក្នុងការចាក់វ៉ាក់សាំង និងការព្យាបាល
- ជួយធ្វើឱ្យប្រាក់ចំណូលគ្រួសារមានការកើនឡើង
- មិនប៉ះពាល់បរិស្ថាន និងសុខភាពសាធារណៈ

**សកម្មភាពទី ៥៖** ការស្វែងយល់ដំណើរការ សាលារៀនចិញ្ចឹមជ្រូក (Farmer Fiel School of pig)

១. ព្យួរក្រដាសផ្ទាំងធំពីរសន្លឹក ដែលមានសរសេរនូវពាក្យៈ " សាលារៀនចិញ្ចឹមជ្រូកគឺជាអ្វី?" និង " សាលារៀនចិញ្ចឹមជ្រូកមានសារៈសំខាន់អ្វីខ្លះ?"

២. សុំឱ្យកសិករឆ្លើយនូវសំណួរខាងលើនេះដោយបំផុសគំនិត ហើយសរសេរចម្លើយនៅលើក្រដាសផ្ទាំងធំ

៣. ប្រាប់ចម្លើយដល់កសិករ ដែលមាននៅក្នុងប្រអប់

៤. ពិភាក្សាអំពីចម្លើយទាំងនេះជាមួយក្រុមកសិករ

*សាលារៀនចិញ្ចឹមជ្រូក និង អត្ថប្រយោជន៍*

**ក. និយមន័យ**

សាលារៀនចិញ្ចឹមជ្រូកគឺជាទីកន្លែងដែលកសិករជួបជុំគ្នា ហើយចុះមើលការអនុវត្តបច្ចេកទេសកសិកម្មដោយផ្ទាល់តាមរយៈការពិភាក្សា ការសិក្សា និងការស្វែងយល់តាមរយៈការអនុវត្តជាក់ស្តែង។

**ខ. គោលបំណង**

**សង្គម**:កសិករមានឱកាសបង្កើតមិត្តភាពថ្មីរកបានដៃគូអាជីវកម្មថ្មី និងផ្លាស់ប្តូរបទពិសោធន៍ពីគ្នាទៅវិញទៅមក។

**មនសិការក្រុម**:កសិករអាចធ្វើសេចក្តីសម្រេចចិត្តដែលផ្តល់ផលប្រយោជន៍ដល់ក្រុមប្រសើរជាងការគិតតែពីផលប្រយោជន៍របស់បុគ្គលម្នាក់ៗ។

**បច្ចេកទេស**: កសិករចេះធ្វើការរួមគ្នា ដើម្បីដោះស្រាយបញ្ហាផ្នែកបច្ចេកទេស បង្កើតទំនាក់ទំនង និង ស្វែងយល់នូវបញ្ហាថ្មីៗដែលខ្លួនជួបប្រទះ។

**ការផ្តល់សិទ្ធិអំណាច**: កសិករទាំងបុរស និងស្ត្រី មានឱកាសរៀនសូត្រធ្វើជាអ្នកដឹកនាំ និងវិធីសាស្ត្រក្នុងការដោះស្រាយបញ្ហាដែលខ្លួនជួបប្រទះ

**សេដ្ឋកិច្ច**: កសិករអាចស្វែងយល់អំពីវិធីសាស្ត្រក្នុងការបង្កើននូវប្រាក់ចំណូលផ្ទាល់ខ្លួន ឬសម្រាប់ក្រុមតាមរយៈការប្រកបមុខរបររួមគ្នា ដូចជាការទិញសំភារៈផលិតកម្មរួមគ្នា ដើម្បីអាចទទួលបានការបញ្ចុះតម្លៃ ហើយពួកគាត់អាចលក់ផលិតផលជាក្រុមដើម្បីទទួលបាននូវតម្លៃសមរម្យ ឬតាមរយៈការជួយគ្នាក្នុងការប្រកបមុខរបរ។

**ការតស៊ូមតិ**:ក្រុមនឹងមានកម្លាំងកាន់តែខ្លាំងក្នុងការតស៊ូមតិដើម្បីធ្វើឱ្យមានការផ្លាស់ប្តូរជាងការតស៊ូមតិតែម្នាក់ៗ

**សកម្មភាព ៦៖** ការបង្កើតផែនការសកម្មភាពសម្រាប់វគ្គបណ្តុះបណ្តាលបន្ត

១. បំផុសគំនិតកសិករអំពីប្រធានបទអ្វីខ្លះដែលគាត់ចង់រៀនទាំងផ្នែកទ្រឹស្តីនិងការអនុវត្ត

២. សរសេរចំលើយរបស់គាត់ដាក់លើក្រដាស់ផ្ទាំងធំ

៣. បង្កើតផែនការសកម្មភាពរួមគ្នា (មើលឧបសម្ព័ន្ធ១)

**សកម្មភាព ៧៖** ការសិក្សាអំពីយេនឌ័រ

១. សួរកសិករប្រុស និងស្រីផ្សេងៗគ្នា តើកត្តាអ្វីខ្លះដែលជាឧបសគ្គរាំងក្នុងការចូលរួមវគ្គបណ្តុះបណ្តាល? តើមានដំណោះស្រាយអ្វីខ្លះ ដើម្បីឱ្យគាត់មានឱកាសចូលរួមវគ្គបណ្តុះបណ្តាល?

២. កត់ត្រាចំលើយ និងយោបល់របស់គាត់ដើម្បីពិចារណា



**ជំនួយស្មារតីសម្រាប់អ្នកសម្របសម្រួល**

- អ្នកអនុវត្តការចិញ្ចឹមជ្រូកផ្ទាល់ក្នុងគ្រួសារចាំបាច់ត្រូវចូលរួមរៀនក្នុងវគ្គបណ្តុះបណ្តាល។
- ករណីអ្នកអនុវត្តការចិញ្ចឹមជ្រូកផ្ទាល់ក្នុងគ្រួសារអវត្តមានអ្នកមកជំនួសត្រូវប្រាប់ពត៌មានទៅដល់អ្នកចិញ្ចឹមផ្ទាល់។

<u>**សកម្មភាពទី ៨៖**</u> ល្បែងថាមពល ខ: ការលេងល្បែងខ្សឹប (ធ្វើក៏បាន មិនធ្វើក៏បាន)

១. ប្រាប់ឱ្យកសិករអង្គុយជារង្វង់

២. ខ្សឹបកសិករដំបូងគេដែលនៅក្បែរអ្នកអំពីរឿងរ៉ាវមួយដែលមានសាច់រឿងជាច្រើន (មើលក្នុងប្រអប់ខាងក្រោម)

៣. ប្រាប់ឱ្យកសិករនោះខ្សឹបប្រាប់រឿងដដែលនេះទៅកាន់កសិករបន្ទាប់ទៀត

៤. បន្តធ្វើដូច្នេះរហូតទាល់តែគ្រប់គ្នា

៥. សួរកសិករចុងក្រោយគេឱ្យរៀបរាប់រឿងនោះឡើងវិញហើយធ្វើការប្រៀបធៀបវាជាមួយនឹងសាច់រឿងដើម

៦. ចុងក្រោយធ្វើការសន្និដ្ឋានដោយនិយាយថាអ្នកដែលទទួលខុសត្រូវការងារពិតប្រាកដគួរតែចូលរៀនឱ្យបានគ្រប់គ្រាន់ព្រោះវាជាប់ទាក់ទងនឹងការងារដែលគាត់ធ្វើ

| |
|---|
| □□□□□□□□□<br>ណារីបានទៅផ្សារទិញបានកូនជ្រូក៥ក្បាល គាត់ចំណាយអស់ ៥០០.០០០រៀល |

<u>**សកម្មភាពទី ៩៖**</u> ការជ្រើសរើសកសិករនិងទីកន្លែងសម្រាប់ធ្វើបង្ហាញ

១. សួរកសិករនូវសំណួរដូចខាងក្រោមនេះ

ក. តើយើងត្រូវមើលទៅលើលក្ខណៈសម្បត្តិអ្វីខ្លះនៅពេលដែលយើងជ្រើសរើសកសិករណាម្នាក់ឱ្យធ្វើបង្ហាញ?

ខ. តើយើងត្រូវមើលទៅលើលក្ខណៈវិនិច្ឆ័យអ្វីខ្លះនៅពេលដែលយើងជ្រើសរើសទីកន្លែងសម្រាប់ធ្វើបង្ហាញ?

២. ប្រៀបធៀបចម្លើយរបស់កសិករជាមួយចម្លើយដែលមានក្នុងឧបសម្ព័ន្ធ ២

៣. ពិភាក្សាអំពីចម្លើយទាំងនោះ ហើយកត់ត្រានូវចម្លើយដែលបានឯកភាពគ្នានោះ

<u>**សកម្មភាពទី ១០៖**</u> បទបញ្ហាផ្ទៃក្នុង

១. ប្រាប់ឱ្យកសិករលើកជាគំនិតអំពីបទបញ្ហាសម្រាប់ដើរតាមក្នុងដំណើរការបណ្តុះបណ្តាល

២. សរសេរបទបញ្ហាផ្ទៃក្នុងនោះនៅលើក្រដាសផ្ទាំងធំ រួចហើយបន្ថែមគំនិតដែលមាននៅក្នុងឧបសម្ព័ន្ធ ៣

៣. បន្ថែមគំនិតទៀតពីឧបសម្ព័ន្ធ៣

## ឧបសម្ព័ន្ធ១៖ ទម្រង់សម្រាប់ការវិភាគវគ្គបណ្ដុះបណ្ដាល

| សកម្មភាព/ប្រធានបទ | អ្នកសម្រេចចិត្ត? បុរស/ស្ត្រី | អ្នកធ្វើសកម្មភាព? បុរស/ស្ត្រី | កាលបរិច្ឆេទ | ទីកន្លែង (ពិនិត្យជាមួយនិងបុរសនិងស្ត្រី) | ពេលវេលា (ពិនិត្យជាមួយនិងបុរសនិងស្ត្រី) |
|---|---|---|---|---|---|
| សេចក្ដីផ្ដើមវគ្គ | | | | | |
| ទ្រុង | | | | | |
| ការជ្រើសរើសពូជ | | | | | |
| ចំណី | | | | | |
| ការថែទាំការពារ | | | | | |
| ការថែទាំសុខភាព | | | | | |
| វិភាគសេដ្ឋកិច្ច | | | | | |
| ផលប៉ះពាល់បរិស្ថាន | | | | | |
| ផ្សេងៗ | | | | | |

## ឧបសម្ព័ន្ធ២៖ លក្ខខណ្ឌជ្រើសរើសកសិករនិងទីកន្លែងសម្រាប់ធ្វើបង្ហាញ



ជំនួយស្មារតី៖
ការផ្ទេរបច្ចេកទេសមួយជោគជ័យគឺអាស្រ័យទៅលើការជ្រើសរើសកសិករ និងទីកន្លែងធ្វើបង្ហាញ ដូច្នេះការកំណត់ជ្រើសរើសកសិករ និងទីកន្លែងធ្វើបង្ហាញជាកត្តាសំខាន់។

<u>ល័ក្ខខ័ណ្ឌជ្រើសរើសកសិករសម្រាប់ធ្វើបង្ហាញ:</u>

- ជាកសិករឧស្សាព្យាយាមដែលរស់នៅអចិន្ត្រៃក្នុងភូមិជាមួយគ្នា
- ជាកសិករគំរូ ឬភ្នាក់ងារសុខភាពសត្វភូមិ ឬ ភ្នាក់ងារផ្សព្វផ្សាយកសិកម្មភូមិ
- ចេះអាន និង សរសេរ
- ស្ម័គ្រចិត្ត ផ្តល់ទីកន្លែងសមស្របសម្រាប់ធ្វើបង្ហាញ
- ស្ម័គ្រចិត្តធ្វើការងារក្រៅពីការងារប្រចាំថ្ងៃរបស់ខ្លួន ដើម្បីមើលថែទាំការធ្វើបង្ហាញ និងកត់ត្រាទិន្នន័យឲ្យបានត្រឹមត្រូវ និងទៀងទាត់
- ចេះចែករំលែកបទពិសោធន៍ និងផ្ទេរចំណេះដឹងដល់កសិករផ្សេងៗទៀត

<u>ល័ក្ខខ័ណ្ឌជ្រើសរើសទីកន្លែងសម្រាប់ធ្វើបង្ហាញ:</u>

- ដីទួលមិនលិចទឹក
- មានពន្លឺគ្រប់គ្រាន់
- មានទីធ្លាសមស្រប
- ឆ្ងាយពីទីប្រជុំជន និងរោងចក្រ

## ឧបសម្ព័ន្ធ៣៖ បទបញ្ជាផ្ទៃក្នុង

| ឧទាហរណ៍អំពីគោលការណ៍គ្រឹះ |
|---|
| • មកចូលរួមឱ្យទាន់ពេល និងទៀងទាត់<br>• ស្ម័គ្រចិត្តចែករំលែកបទពិសោធន៍ និង រៀនសូត្រអ្វីដែលបានរៀន<br>• ហ៊ានឡើងសួរសំណួរពេលមានចម្ងល់ នៅពេលដល់វេនរបស់អ្នកត្រូវសួរ ឬ រង់ចាំឱ្យគេសួរចប់<br>• យកចិត្តទុកដាក់ស្តាប់ និងគោរពនូវអ្វីដែលបុរស-ស្ត្រីទាំងអស់គេចង់និយាយដោយមិននិយាយកាត់ពួកគេ<br>• ហាមផ្លាស់ប្តូរអ្នកចូលរួម<br>• គ្មានការរើសអើង (ស្វាគមន៍គ្រប់គ្នា)!<br>• ហាមសេពគ្រឿងស្រវឹង |

# ជំពូកទី ២៖ ការជ្រើសរើសពូជ

រយៈពេល: ៤ម៉ោង

គោលបំណង:

- ណែនាំកសិករឲ្យស្គាល់ពីលក្ខណៈពិសេសនៃប្រភេទពូជជ្រូកក្នុងស្រុក និងពូជជ្រូកនាំចូល
- ណែនាំកសិករឱ្យចេះជ្រើសរើសពូជ

សម្ភារៈ

ផ្ទាំងក្រដាស់ធំ ហ្វឺត ស្កុត ក្រដាស់ អា៤ ផ្ទាំងរូបភាព និងឧបសម្ព័ន្ធ១

ដំណើរការៈ

**សកម្មភាព ១៖** ការជ្រើសរើសពូជ

១. សួរកសិករថា តើកន្លងមកជ្រើសរើសពូជជ្រូកចិញ្ចឹមដោយរបៀបណា?

២. សួរកសិករថា តើការជ្រើសរើសពូជជ្រូកមានសារៈសំខាន់ដែរ ឬទេ? ហេតុអ្វី?

៣. សួរកសិករថា តើការជ្រើសរើសពូជជ្រូកឱ្យបានល្អផ្អែកលើលក្ខណៈវិនិច្ឆ័យអ្វីខ្លះ?

៤. សរសេរចម្លើយរបស់គាត់ដាក់លើផ្ទាំងក្រដាស់ធំ ហើយធ្វើការសន្និដ្ឋាន

៥. ប្រៀបធៀបចម្លើយទាំងនោះជាមួយនឹងចំលើយក្នុងជំនួយសារតីខាងក្រោម

ជំនួយស្មារតី: សារៈសំខាន់នៃការជ្រើសរើសពូជ

- ពូជជ្រូកល្អមានសុខភាពល្អ លូតលាស់លឿន ធន់នឹងបរិស្ថានក្នុងស្រុក ហើយមានតម្រូវការខ្ពស់នៅលើ ទីផ្សារក្នុងស្រុក
- ពូជជ្រូកមេល្អអាចបង្កើតកូនបានច្រើនហើយមានសុខភាពល្អ
- ពូជជ្រូកល្អអាចលក់បានថ្លៃ និងមានផលចំណេញច្រើន

ជំនួយស្មារតី: លក្ខខណ្ឌក្នុងការជ្រើសរើសពូជជ្រូកល្អ

- មានសុខភាពល្អ ស្រែកឮ មានភាពរហ័សរហួន ថ្លោស
- ជ្រូកត្រូវតែមានរូបរាងល្អ មានមាឌធំ ដងខ្លួនវែង ជំហរជើងមាំ ត្រកៀកសាយ ចំនួនដោះលើសពី៦គូនៅត្រង់ជួរ មានចុងដោះច្បាស់លាស់ (ចំពោះបា ពងស្វាសធំ ហើយស្មើ)
- ជ្រូកមានរោមស្តើង និងស្បែកភ្លឺល្អ
- មិនធ្លាប់ឆ្លងជម្ងឺពីមុនមក
- ជ្រើសរើសដែលមានប្រភពច្បាស់លាស់ ជ្រើសរើសយកកូនសារទីពីរ
- បានអនុវត្តកម្មវិធីចាក់វ៉ាក់សាំងត្រឹមត្រូវ
- ធន់នឹងបរិស្ថានក្នុងស្រុក
- អាចរកបាននៅក្នុងស្រុក
- ពេញនិយមនៅលើទីផ្សារ

សកម្មភាព ២៖ ប្រភេទពូជជ្រូកផ្សេងៗ

១. សួរកសិករថា តើសព្វថ្ងៃនេះពួកគាត់ចិញ្ចឹមប្រភេទពូជជ្រូកអ្វី?
២. បង្ហាញរូបភាពពូជជ្រូកផ្សេងៗឱ្យកសិករមើល (មើលឧបសម្ព័ន្ធ១) ហើយសួរគាត់ថា តើមួយណា ជាពូជជ្រូកក្នុងស្រុក ពូជកូនកាត់ និងមួយណាជាពូជនាំចូល?
៣. ពន្យល់ប្រាប់ពួកគាត់ពីភាពខុសប្លែកគ្នា និងអត្ថប្រយោជន៍នៃពូជនីមួយៗ (មើលឧបសម្ព័ន្ធ១)

សកម្មភាពទី ៣៖ ការត្រៀមដាក់ជ្រូកចិញ្ចឹម

១. សួរកសិករថាតើត្រូវរៀបចំទុកជាមុនអ្វីខ្លះដែលពួកគាត់ត្រូវធ្វើមុនពេលយកជ្រូកមកចិញ្ចឹម?
២. ពិភាក្សាចំលើយក្នុងក្រុម
៣. បន្ថែមគំនិតខ្លះទៀតដោយផ្អែកលើជំនួយស្មារតីខាងក្រោម

ជំនួយស្មារតី: សកម្មភាពបំរុង

- សំអាតទ្រុងជ្រូក ហើយបាចកំបោរសម្លាប់មេរោគមុន១០ថ្ងៃ មុននឹងជ្រូកមកដល់
- លាងសំអាតកំបោរចេញមុន១ថ្ងៃ មុននឹងដាក់ជ្រូកចូលទ្រុង
- រៀបចំស្នូកទឹកនិងចំណី
- ស្នូកទឹក និងចំណីធ្វើឱ្យទៅតាមអាយុកាលរបស់ជ្រូក (តូច ឬធំ) (មើលបន្ថែមនៅជំពូក៤)

សកម្មភាពទី ៩៖ ការដឹកជញ្ជូន និងការថែទាំបឋម

១. សួរកសិករថាតើកន្លងមកការដឹកជញ្ជូនជ្រូក និងថែទាំជ្រូកដែលទើបតែមកដល់យ៉ាងដូចម្តេច?

២. ពិភាក្សាចំលើយក្នុងក្រុម

៣. ជាគំនិតបន្ថែមសូមមើលជំនួយស្មារតីក្នុងប្រអប់ខាងក្រោម

**ជំនួយស្មារតី: វិធីសាស្រ្តដឹកជញ្ជូនជ្រូក**

- ត្រូវដឹកជញ្ជូនពេលព្រឹក ឬពេលល្ងាចត្រជាក់
- ពេលដឹកជញ្ជូនកុំដាក់កូនជ្រូកក្នុងទ្រុងច្រើនពេកពីព្រោះវាអាចធ្វើជ្រូកខ្សោយ ហើយអាចបណ្តាលឱ្យបាក់ជើង ឬអាចងាប់ដោយសារតែជាន់គ្នា
- ទ្រុងដឹកត្រូវមានខ្យល់ចេញចូលឱ្យបានគ្រប់គ្រាន់ តែកុំឱ្យជ្រូកត្រូវកំលាំងខ្យល់ខ្លាំងពេក

**ជំនួយស្មារតី: ពេលដឹកមកដល់កន្លែង**

- ដាក់ជ្រូកដែលទើបតែមកដល់ថ្មីនៅក្នុងទ្រុងផ្សេង ដើម្បីតាមដានសុខភាព
- ១ ទៅ ២ ម៉ោងក្រោយពេលដឹកជ្រូកមកដល់ ទើបផ្តល់ទឹក និងចំណី

## ឧបសម្ព័ន្ធ១៖ ពូជជ្រូកនិយមបំផុតក្នុងប្រទេសកម្ពុជា

*ក- ពូជជ្រូកក្នុងស្រុក*

ពូជជ្រូកក្នុងស្រុកមានដូចជា៖ ពូជជ្រូកហៃណាំ ពូជជ្រូកកណ្ដុរ ពូជជ្រូកដំរី ពូជជ្រូកកំពត ។ល។

<u>គុណសម្បត្តិ:</u>

- ធន់នឹងជំងឺ និងអាកាសធាតុក្នុងស្រុក
- មិនរើសចំណី
- ផ្ដល់កូនច្រើន (សាយកូន) និងចេះថែកូន
- ងាយរកបាននៅតាមតំបន់ជនបទ

<u>គុណវិបត្តិ:</u>

- លូតលាស់យឺត ហើយមាឌតូច (ពី៦-១២ខែ ទើបបានសាច់៦០គីឡូក្រាម)
- សាច់ក្រហមតិច តែខ្លាញ់ច្រើន
- តម្លៃជ្រូករស់ថោក



ពូជជ្រូកហៃណាំ



ពូជជ្រូកកណ្ដុរ



ពូជជ្រូកដំរី

*ខ-ពូជជ្រូកនាំចូល*

ពូជជ្រូកនាំចូលមាន៖ ពូជយ៉កស៊ៀរ (Yorkshire) ឡែនរ៉េស (Landrace) ឌុយរ៉ុក (Duroc) ហែមស៊ៀរ (Hampshire) ។ល។

<u>គុណសម្បត្តិ</u>

- ការលូតលាស់លឿន
- សាច់ក្រហមច្រើន ខ្លាញ់តិច
- មានតម្រូវការទីផ្សារខ្ពស់

<u>គុណវិបត្តិ:</u>

- មិនសូវធន់នឹងជំងឺ និងអាកាសធាតុក្នុងស្រុក
- ទាមទារឱ្យមានល័ក្ខខ័ណ្ឌថៃទាំ និងគ្រប់គ្រងខ្ពស់
- រើសចំណី



ពូជជ្រូកយ៉កស៊ៀ
Yorkshire Large White



ពូជជ្រូកឡែនរ៉េស
Landrace



ពូជជ្រូកហែមស៊ៀ
Hampshire



ពូជជ្រូកឌុយរ៉ុក
Duroc

*ពូជជ្រូកកូនកាត់*

- ពូជនេះជាការបង្កាត់រវាងពូជក្នុងស្រុក និងនាំចូល ដែលផ្តល់នូវអត្ថប្រយោជន៍ចម្រុះ
- ការលូតលាស់ល្អ
- ធន់នឹងជំងឺ និងអាកាសធាតុក្នុងស្រុកបានល្អ

សំគាល់:

ហាមបង្កាត់ជ្រូកដែលមានសណ្តានជាមួយគ្នា បណ្តាលឲ្យជាន់ឈាមគ្នា ចិញ្ចឹមក្រធំ និងងាយទទួលជំងឺ។

# ជំពូកទី ៣៖ ការសាងសង់ទ្រុង

<u>រយៈពេល:</u> ៤ម៉ោង

<u>គោលបំណង:</u>

- ជម្រុញឱ្យកសិករចិញ្ចឹមជ្រូកក្នុងទ្រុងតាមលក្ខណៈបច្ចេកទេស
- ឱ្យកសិករចេះពីការសាងសង់ទ្រុង និងអត្ថប្រយោជន៍នៃការចិញ្ចឹមជ្រូកក្នុងទ្រុង

<u>សម្ភារៈ</u>

**ផ្នែកទ្រឹស្តី:** ហ្វឺត ផ្ទាំងក្រដាស់ធំ ស្កុត ឯកសារមេរៀន និងឧបសម្ព័ន្ធ ១ អំពីរូបភាពទ្រុងជ្រូក
**ផ្នែកអនុវត្តន៍:** ឬស្សី ស្លឹក ស្បូវ ឬស័ង្កសី ដែកគោល ខ្សែលួស សសរឈើ ចបជីក ចបកាប់ ពូថៅ រណា ស្នូកចំណី និងទឹក កំបោរស ស៊ីម៉ង់ត៍ ខ្សាច់ ដែក និងអំបោស

<u>ដំណើរការ:</u>

សកម្មភាព ១៖ អត្ថប្រយោជន៍នៃទ្រុងជ្រូក

១. សួរកសិករថា តើកន្លងមកគាត់ចិញ្ចឹមជ្រូកក្នុងទ្រុងដែរឬទេ?

២. សួរគាត់ទៀតថា តើការចិញ្ចឹមជ្រូកក្នុងទ្រុងមានអត្ថប្រយោជន៍អ្វីខ្លះ?

៣. សរសេរចម្លើយដាក់លើផ្ទាំងក្រដាស់ធំ

៤. ប្រៀបធៀបចម្លើយជាមួយនឹងចម្លើយក្នុងជំនួយស្មារតីខាងក្រោម៖

**ជំនួយស្មារតី: អត្ថប្រយោជន៍នៃការចិញ្ចឹមជ្រូកក្នុងទ្រុង**

- ✓ ជួយការពារជ្រូកពីខ្យល់ ភ្លៀង ក្តៅ និងកំដៅព្រះអាទិត្យ
- ✓ ងាយស្រួលថែទាំ ផ្តល់ចំណី ទឹក ចាក់វ៉ាក់សាំង ព្យាបាលជំងឺផ្សេងៗ និងតាមដានសុខភាព
- ✓ ងាយស្រួលគ្រប់គ្រងជ្រូក:
  - ○ បំបែកកូនចេញពីមេជ្រូក
  - ○ ដាក់ជ្រូកទៅតាមប្រភេទ និងអាយុរបស់វា
  - ○ បំបែកជ្រូកឈឺចេញពីជ្រូកជា
- ✓ ងាយស្រួលក្នុងការធ្វើអនាម័យ
- ✓ ការពារសុខុមាលភាពមនុស្ស (ដោយមិននៅលាយឡំជាមួយជ្រូក)
- ✓ ទប់ស្កាត់ការឆ្លងជំងឺផ្សេងៗពីខាងក្រៅ
- ✓ ស្រួលចាប់លក់

**សកម្មភាព ២៖** លក្ខខណ្ឌតម្រូវនៃការសាងសង់ទ្រុង

១. សួរកសិករថា តើគាត់ធ្លាប់សាងសង់ទ្រុងដែរឬទេពីមុនមក?
២. តើការសាងសង់ទ្រុងត្រូវផ្តោតលើអ្វីខ្លះ (ទីតាំង សម្ភារៈ)?
៣. សរសេរចម្លើយដាក់លើក្រដាសផ្ទាំងធំ
៤. ពិភាក្សាចម្លើយក្នុងក្រុម ហើយមើលជំនួយស្មារតីខាងក្រោម៖

៥. បង្ហាញរូបភាពនៃប្រភេទទ្រុងជ្រូកផ្សេងៗគ្នា ហើយពន្យល់ប្រាប់គាត់ពីបច្ចេកទេស សម្ភារៈ ទំហំ និងភាពខុសគ្នា (មើលឧបសម្ព័ន្ធ១)
៦. នាំកសិករឱ្យចាប់ផ្តើមសាងសង់ទ្រុងទាំងអស់គ្នា



**ជំនួយស្មារតី:**
ត្រូវប្រាកដថាកសិករធ្វើបង្ហាញបានត្រៀមគ្រប់សម្ភារៈចាំបាច់ទាំងអស់ ដើម្បីចាប់ផ្តើមធ្វើទ្រុងជ្រូកក្នុងពេលវគ្គបណ្តុះបណ្តាល។

**ជំនួយស្មារតី:** លក្ខខណ្ឌតម្រូវនៃការសាងសង់ទ្រុង

- ត្រូវសង់នៅលើទីខ្ពស់ដែលមិនលិចទឹក ដក់ទឹក រឺមានភក់ជ្រាំ
- ត្រូវសង់នៅឆ្ងាយពីទីប្រជុំជន ផ្លូវថ្នល់ កសិដ្ឋាន លំនៅដ្ឋាន (តែមិនឆ្ងាយពេកពីលំនៅដ្ឋានទេ)
- ត្រូវសង់តាមលក្ខណៈបច្ចេកទេស:
    - បណ្តោយថ្ងៃ
    - មានខ្យល់ចេញចូលល្អ
    - មានរនាំងការពារខ្យល់រឺភ្លៀងខ្លាំង
    - មានពន្លឺគ្រប់គ្រាន់
    - កម្រាលមិនគ្រើមពេក មិនរលោងពេក រាងជម្រេល និងមានប្រព័ន្ធបង្ហូរកាកសំណល់ត្រឹមត្រូវ
    - ត្រូវមានទីកន្លែងគ្រប់គ្រាន់សម្រាប់ដាក់ស្នូកទឹក និងចំណី
- ត្រូវសង់ទ្រុងទៅតាមប្រភេទសត្វនីមួយៗ៖ ជ្រូកបា មេជ្រូកដើម មេជ្រូកបំបៅដោះ កូនជ្រូកផ្តាច់ដោះ ជ្រូកសាច់ និងជ្រូកឈឺ
- ទ្រុងជ្រូកចាំបាច់ត្រូវមានទ្វារពីរ (មុខមួយ ក្រោយមួយ) ងាយស្រួលក្នុងការចល័តជ្រូក
- ត្រូវសម្អាតទ្រុងជ្រូកជាប្រចាំ (យ៉ាងហោចណាស់ពីរដងក្នុងមួយថ្ងៃ)

## ឧបសម្ព័ន្ធ១៖ ប្រភេទទ្រុងជ្រូកផ្សេងៗគ្នា

*១- ទ្រុងសង់បណ្តោយពន្លឺថ្ងៃ*



ប្រភេទទ្រុងទី១៖

១. ជួយការពារជ្រូកពីកំដៅថ្ងៃខ្លាំងដែលអាចឲ្យប៉ះពាល់សុខភាពជ្រូក(ជាពិសេសនៅពេលថ្ងៃត្រង់)

២. ពេលព្រឹកកំដៅថ្ងៃក្នុងទ្រុងល្អ ហើយជួយផ្តល់វីតាមីនឌីគ្រប់គ្រាន់សម្រាប់ជ្រូក

***២- ទ្រុងជិះចូលខ្លី***





ប្រភេទទ្រុងទី២៖

១. កសិករតំបន់ជនបទក្នុងប្រទេសកម្ពុជានិយមចូលចិត្តទ្រុងប្រភេទនេះ

២. មិនចំណាយថវិកាច្រើនក្នុងការសាងសង់

៣. សមស្របក្នុងការចិញ្ចឹមជាលក្ខណៈទ្រង់ទ្រាយតូច

## ៣- ទ្រុងដំបូលគោម





**ប្រភេទទ្រុងទី៣៖**

- ប្រទេសកម្ពុជាក៏និយមប្រើទ្រុងប្រភេទនេះដែរ
- សមស្របក្នុងការចិញ្ចឹមជាលក្ខណៈទ្រង់ទ្រាយតូច មធ្យម និង ធំ
- អាចមានដំបូលមួយជាន់ ឬពីរជាន់

## *៤- ទំហំ*

ការរៀបចំទ្រុង ប្រភេទទ្រុង និងទំហំទ្រុងអាស្រ័យទៅតាមប្រភេទ ពូជជ្រូក និងទៅតាមតំបន់ ឬទីតាំងជាក់ស្តែងដែលយើងអាចធ្វើបាន (ទីកន្លែង និងហិរញ្ញវត្ថុ)។ ប៉ុន្តែចាំបាច់ត្រូវមានក្រឡាផ្ទៃសមស្របសម្រាប់ប្រភេទជ្រូកនីមួយៗដូចមានខាងក្រោម៖

| ប្រភេទជ្រូក | ទំហំទ្រុង (ម៉ែត្រ) | កម្ពស់ទ្វារ(ម៉ែត្រ) |
|---|---|---|
| ជ្រូកជំទង់ | ១x២ | ១ |
| មេជ្រូកដើម/មេបំរុង | ០.៦៥x២.២០ | ១ |
| ជ្រូកបាមានកន្លែងសម្រាប់បង្កាត់ | ២.៣ x៤ | ១-១.៥ |
| ជ្រូកមេបំបៅដោះ | ១.៥ x២ | ១ |
| មេជ្រូកកើតកូន | ២ x២.៣ | ១ |
| កូនជ្រូកផ្តាច់ដោះ | ២.៥ x៣ សម្រាប់ ១២ក្បាល | ០.៦ |
| ជ្រូកសាច់ទំងន់ ៣០-៦០គ.ក | ០.៧ x១ | ១ |
| ជ្រូកសាច់ទំងន់៦១គ.ក ដល់លក់ | ១.២ x១ | ១ |

*(ប្រភព៖ USAID សហការជាមួយនាយកដ្ឋានផលិតកម្ម និងបសុព្យាបាល ២០១១)*

ចំពោះទ្រុងត្រូវមានទ្វាពីរ មុខ និងក្រោយដើម្បីងាយស្រួលក្នុងការចល័តជ្រូកពីកន្លែងមួយទៅកន្លែងមួយ។ ចំពោះទ្រុងសម្រាប់មេត្រូវរៀបចំជា៣ផ្នែក៖

- ទ្រុងសម្រាប់មេទំហំ 0.៦៥មx២.២ម
- ទីតាំងសម្រាប់កូនដេកទំហំ 0.២មx២.២ម
- ទីតាំងសម្រាប់កូនស៊ីចំណី និងផឹកទឹក 0.៦៥មx២.២ម

# ជំពូកទី ៨៖ ចំណីជ្រូក

<u>រយៈពេល:</u> ១ថ្ងៃ

<u>គោលបំណង:</u>

- ឱ្យកសិករស្គាល់ពីប្រភេទ បរិមាណ និងគុណភាពចំណីសម្រាប់ប្រភេទជ្រូកនិមួយៗ
- ឱ្យកសិករចេះពីវិធីផ្សំពីវត្ថុធាតុដើមដែលមានស្រាប់ក្នុងមូលដ្ឋាន
- ឱ្យកសិករចេះទុកដាក់ និងផ្តល់ចំណីជ្រូកឱ្យបានត្រឹមត្រូវ

<u>សម្ភារ:</u>
ក្រដាសផ្ទាំងធំ ហ្វឺត ស្កុត ផ្ទាំងរូបភាព វត្ថុធាតុដើម ឧបសម្ព័ន្ធ១ និង២

<u>ដំណើរការ</u>
សកម្មភាពទី១៖ ចំណីជ្រូកដែលកសិករប្រើ

១. សួរកសិករថា តើគាត់ធ្លាប់ឱ្យជ្រូកស៊ីចំណីអ្វីខ្លះ?

២. សរសេរចម្លើយដាក់លើក្រដាសផ្ទាំងធំដាក់ក្នុងតារាងខាងក្រោម

| ចំណីជ្រូកធ្លាប់ប្រើ | ចំណីជ្រូកមិនធ្លាប់ប្រើ |
|---|---|
| ១..............................<br>២..............................<br>៣.............................. | ១..............................<br>២..............................<br>៣.............................. |

៣. មើលក្នុងជំនួយស្មារតីខាងក្រោម ហើយថែមគំនិតទៅក្នុងតារាងជួរឈរទីពីរបន្ថែមទៀត រួចពន្យល់ប្រាប់កសិករពីកន្លែងដែលពួកគាត់អាចរកចំណីបាន

**ជំនួយស្មារតី: ប្រភេទចំណីសម្រាប់ជ្រូក**

- កន្ទក់ ចុងអង្ករ ពោត និងសណ្តែក
- ត្រកួន ចកបាយទា កំប្លោក
- ស្លឹកមន កន្ទំថេត ផ្ទី ស្លឹកដំឡូងជ្វា ដំឡូងមី ស្លឹកបាស ស្លឹកម្រុំ និង ដើមត្រាវនិងស្លឹក
- កំពឹស កូនត្រីតូចៗ ក្បាលត្រី
- កាកសំណល់ផ្ទះបាយ បាយស្រា និងកាកសំណល់តាមភោជនីយដ្ឋាន

**សំគាល់:** ព្យាយាមលាយវត្ថុធាតុដើមឱ្យបាន២ទៅ៣ប្រភេទ ផ្សេងៗគ្នាដូចជា រុក្ខជាតិ ធញ្ញជាតិ និងសត្វជាដើម។

**សកម្មភាពទី ២៖** សារធាតុចិញ្ចឹមចាំបាច់សម្រាប់ជ្រូក

១. សួរកសិករថា តើសារធាតុចិញ្ចឹមចាំបាច់សម្រាប់ជ្រូកមានអ្វីខ្លះ?

២. កត់ត្រាចម្លើយចូលក្នុងក្រដាសផ្ទាំងធំ

៣. ប្រៀបធៀបចម្លើយគាត់ជាមួយនិងចម្លើយក្នុងជំនួយស្មារតីខាងក្រោម

**ជំនួយស្មារតី: សារធាតុចិញ្ចឹមចាំបាច់សម្រាប់ជ្រូក**

សារធាតុចិញ្ចឹមមានសារៈសំខាន់ណាស់សម្រាប់ជួយទ្រទ្រង់ ជម្រុញដល់ការលូតលាស់ បន្តពូជ ទប់ទល់ជំងឺ ជំនួយរាងកាយឱ្យរឹងមាំ និងជួយសម្រួលដល់សីតុណ្ហាភាពក្នុងខ្លួនជ្រូក។ សារធាតុចិញ្ចឹមចាំបាច់សម្រាប់ជ្រូកមានដូចជា:

- ប្រូតេអ៊ីន
- ថាមពល
- វីតាមីន
- សារធាតុខនិជ
- ទឹក

កង្វះសារធាតុណាមួយនឹងនាំឱ្យជ្រូកកើតជំងឺផ្សេងៗ ធ្វើឱ្យមុខងារសរីរាង្គមានការប្រែប្រួលខុសពីប្រក្រតី និងធ្វើឱ្យការលូតលាស់ចុះខ្សោយ។

**សំគាល់:** បន្ថែមសារធាតុ ព្រីម៉ិច និងអំបិលទៅក្នុងចំណីឱ្យជ្រូកស៊ីឱ្យបានស្របតាមតម្រូវការ។

៤. សួរកសិករថា តើសារធាតុទាំងនេះផ្តល់អត្ថប្រយោជន៍អ្វីខ្លះ?
៥. ពន្យល់ប្រាប់ពួកគាត់បន្ថែមទៀតនៅក្នុង ឧបសម្ព័ន្ធ១

**សកម្មភាពទី ៣៖** បរិមាណចំណីសម្រាប់ផ្តល់ឱ្យជ្រូក

១. បំផុសគំនិតកសិករអំពីបរិមាណចំណីដែលត្រូវផ្តល់ឱ្យជ្រូកដោយផ្អែកលើប្រភេទផលិតកម្ម និងអាយុកាលរបស់សត្វ
២. កត់ត្រាចម្លើយចូលក្នុងក្រដាសផ្ទាំងធំ
៣. ពន្យល់ប្រាប់ពួកគាត់បន្ថែមទៀតដោយបង្ហាញ ឧបសម្ព័ន្ធ២
៤. ពន្យល់ប្រាប់ពួកគាត់ឱ្យដឹងផងដែរអំពីស្នូកទឹក និងចំណី (មើលឧបសម្ព័ន្ធ៣)

**សកម្មភាពទី៤៖** ការទុកដាក់ចំណីជ្រូក

១. សួរកសិករថា តើគាត់ទុកដាក់ចំណីសម្រាប់ជ្រូកយ៉ាងដូចម្តេច?
២. កត់ត្រាចម្លើយចូលក្នុងក្រដាសផ្ទាំងធំ
៣. ផ្តល់គំនិតដល់កសិករបន្ថែមទៀតដោយផ្អែកលើជំនួយស្មារតីខាងក្រោម

ជំនួយស្មារតី: ការទុកដាក់ចំណីជ្រូក

**ចំណីសើម៖**

- លាយភ្លាម ត្រូវឱ្យស៊ីភ្លាម មិនត្រូវរក្សាទុកយូទេ

**ចំណីស្ងួត៖**

- ទុកក្នុងស្បោងរឺសម្ភារៈផ្សេងទៀតដែលអាចការពារកុំឱ្យទឹកជ្រាបចូលបាន
- ទុកចំណីនៅលើធ្នើរខ្ពស់ផុតពីដី ជៀសវាងទុកផ្ទាល់លើកំរាលឥដ្ឋ
- ទុកចំណីនៅទីកន្លែងស្ងួតដែលមានពន្លឺ និងខ្យល់គ្រប់គ្រាន់
- ការពារចំណី កុំឱ្យសត្វចង្រៃបំផ្លាញ

## ឧបសម្ព័ន្ធ១៖ គម្រូវការចំណីចំប៉ន និងការពន្យល់បកស្រាយ

*ក- <u>ប្រូតេអ៊ីន (ជាតិសាច់)</u>*

*<u>សារៈសំខាន់:</u>*

- ជួយជម្រុញដល់ការលូតលាស់ និងការបន្តពូជ
- ជួយធ្វើឱ្យឆ្អឹងលូតលាស់
- ជួយទ្រទ្រង់ដល់សុខភាព
- ជួយបង្កើតអង់ទីគ័រ និងផលិតអង់ស៊ីមនិងអ័រម៉ូន

*<u>ប្រភព:</u>*

*សត្វ:* ត្រី(ម្សៅត្រី រីត្រីស្ងួត) ម្សៅសាច់ ម្សៅឈាម កំពឹស

*រុក្ខជាតិ:* ធញ្ញាជាតិ សណ្តែកសៀង សណ្តែកបាយ សណ្តែកដី លូ គ្រាប់កៅស៊ូ ចកបាយទា ត្រកួន ស្លឹកកន្ធំថេត ផ្ទីរ

*ខ- <u>ចំណីថាមពល (ម្សៅនិងសារធាតុខ្លាញ់)</u>*

*<u>សារៈសំខាន់:</u>*

- ជួយទ្រទ្រង់សុខភាព និងសារពាង្គកាយ
- ជួយទ្រទ្រង់ដល់មុខងារកោសិកាក្នុងពេលដំណើរការរំលាយអាហារ
- បង្កើន និងរក្សាកំដៅក្នុងខ្លួន ឲ្យមានតុល្យភាព
- ផ្តល់កំលាំងឲ្យសត្វធ្វើសកម្មភាព

*<u>ប្រភព:</u>*

- មើមដំឡូងមី មើមដំឡូងជ្វា មើមត្រាវ
- កន្ទក់ ពោត ចុងអង្ករ
- ខ្លាញ់សត្វ ប្រេងរុក្ខជាតិ កាកដូង
- កាកសំណល់ផ្ទះបាយ កាកស្ករ ស្ករ កាកស្រាបៀរ បាយស្រា (ដាក់ក្នុងកម្រិតមួយកំណត់)

*<u>គ- វីតាមីន</u>*

*<u>សារៈសំខាន់:</u>*

- ជួយទ្រទ្រង់ និងការពារដល់មុខងារសរីរាង្គសត្វក្នុងការប្រើប្រាស់ ឬធ្វើសំយោគសារធាតុចិញ្ចឹម ពីចំណីអាហារ
- ជួយទ្រទ្រង់ដល់សុខភាពសត្វ (ការពារជំងឺ)
- ជួយទ្រទ្រង់ដល់ផលិតកម្ម (សាច់ ឆ្អឹង និងការបន្តពូជ....)

*ប្រភព:*

- វីតាមីនមាននៅក្នុងរុក្ខជាតិបៃតង (ជាពិសេសប្រភេទស្លឹកដូចជា ស្លឹកមន ស្លឹកម្រុំ បន្លែស្លឹករុក្ខជាតិស្មៅ)
- ធញ្ញាជាតិ និងដើមរុក្ខជាតិពណ៌លឿង (ការ៉ុត ផ្លែឈើទុំ ផ្លែល្ពៅទុំ)
- ថ្លើមសត្វ សំបកស៊ុត និងខ្លាញ់ត្រី
- ពន្លឺព្រះអាទិត្យ

**សំគាល់:** សារធាតុវីតាមីនងាយនឹងបាត់បង់រឺខូចខាតបើត្រូវកំដៅថ្ងៃរឺពន្លឺខ្លាំងពេក ដូច្នេះចាំបាច់ត្រូវឱ្យជ្រូកស៊ីផ្លែឈើ បន្លែ និងរុក្ខជាតិស្រស់ៗ។

***ឃ- សារធាតុខនិជ***

*សារៈសំខាន់:*

- ជួយធ្វើឱ្យឆ្អឹងលូតលាស់និងជម្រុញដល់ការលូតលាស់សារពាង្គកាយ
- ជួយការពារទប់ស្កាត់ជម្ងឺ (ឆ្អឹងបាក់ ជើងទន់ខ្សោយ)
- ជួយសំយោគ និងស្រូបយកសារធាតុចិញ្ចឹម

*ប្រភព:*

- ដើមរុក្ខជាតិបៃតង បន្លែ
- ម្សៅត្រី
- ម្សៅឆ្អឹង សំបកខ្យង ខ្ចៅ គ្រំ ងាវ ក្តាម
- ម្សៅទឹកដោះ
- អំបិល

***ង- ទឹក***

*សារៈសំខាន់:*

- ជួយសម្របសម្រួលមុខងារសរីរាង្គ
- ជួយរក្សាតុល្យភាពកំដៅក្នុងខ្លួនសត្វ
- ជួយបញ្ជូនសារធាតុចិញ្ចឹមទៅកាន់ផ្នែកផ្សេងៗនៃសារពាង្គកាយសត្វ
- ជួយរំលាយអាហារ និងការផលិតទឹកដោះ

**សំគាល់:** ទឹកដែលឱ្យជ្រូកផឹកត្រូវតែស្អាតនិងមានអនាម័យ។

## ឧបសម្ព័ន្ធ២៖ បរិមាណចំណីជ្រូក

បរិមាណចំណីគឺត្រូវឱ្យទៅតាមអាយុកាលរបស់ជ្រូកនិងប្រភេទផលិតកម្ម (ឧ. យកសាច់ រឺបន្តពូជ)

### ជម្រើសទី១

| ល.រ | សមាសធាតុផ្សំ | បរិមាណធាតុផ្សំចំណីគិតជា(គក្រ)សម្រាប់ចំណី១០០គក្រ | | | |
|---|---|---|---|---|---|
| | | កូនជ្រូកផ្តាច់ដោះ មានអាយុពី៤-៩ សប្តាហ៍ | ជ្រូកសាច់ មានអាយុលើសពី៩សប្តាហ៍ | មេជ្រូកនិង ជ្រូកបាក | ជ្រូកបំបៅដោះ |
| ១ | ពោត | ៥ | | | |
| ២ | ចុងអង្ករ | ៤៩ | ៥៨ | ៥០ | ៥៦ |
| ៣ | កន្ទក់ | | ២០ | ៣០ | ២០ |
| ៤ | សណ្តែកសៀង | ៣២ | ១៥ | ១៣ | ១៦ |
| ៥ | ម្សៅត្រី (ត្រី) | ៥ | ៤ | ៤ | ៤ |
| ៦ | សំបកលាស គ្រំ ខ្យង ខ្ចៅ (DCP) | ៣ | ២ | ២ | ៣ |
| ៧ | ស្ករសរ | ២ | ០ | ០ | ០ |
| ៨ | ប្រេងចំអិន | ២ | ០ | ០ | ០ |
| ៩ | អំបិល | ០.៥ | ០.៥ | ០.៥ | ០.៥ |
| ១០ | ព្រីម៉ិច | ០.៥ | ០.៥ | ០.៥ | ០.៥ |
| សរុប | | ១០០ | ១០០ | ១០០ | ១០០ |

## ជម្រើសទី២

| ល.រ | សមាសធាតុផ្សំ | បរិមាណធាតុផ្សំចំណីគិតជា(គក្រ)សម្រាប់ចំណី១០០គក្រ | | | | |
|---|---|---|---|---|---|---|
| | | កូនជ្រូកផ្តាច់ដោះ ដល់ទម្ងន់២០គ.ក្រ | ជ្រូកសាច់ទម្ងន់ពី ២០-៦០គ.ក្រ | ជ្រូកសាច់ទម្ងន់ពី ៦០ គ.ក្រ ដល់លក់ | មេ និងបា | មេបំបៅកូន |
| ១ | ពោត | ០ | ២០ | ៣០ | ២០ | ២៥ |
| ២ | ចុងអង្ករ | ៥៥ | ០ | ០ | ០ | ០ |
| ៣ | កន្ទក់ | ០ | ២៥ | ៣០ | ៣៣ | ២៨ |
| ៤ | មើមដំឡូងមី | ០ | ១០ | ១៣ | ២០ | ២០ |
| ៥ | កាកសណ្តែកសៀង | ២២ | ២០ | ១០ | ១០ | ១០ |
| ៦ | កន្ទក់សណ្តែកបាយ | ០ | ១០ | ១០ | ១២ | ១០ |
| ៧ | ម្សៅត្រី (ត្រី) | ៥ | ៤ | ៣ | ២ | ៣ |
| ៨ | សំបកលាស គ្រំ ខ្យង ខ្ទៅ (DCP) | ០ | ១ | ១ | ១ | ១ |
| ៩ | ក្បាលបង្គា | ០ | ៤ | ៣ | ២ | ៣ |
| ១០ | ប្រេងសណ្តែក | ៣ | ០ | ០ | ០ | ០ |
| ១១ | ព្រីម៉ិច | ០ | ០.៥ | ០.២៥ | ០ | ០.២៥ |
| ១២ | បាសម៉ិច (Prestarter) | ៥ | ០ | ០ | ០ | ០ |
| ១៣ | ទឹកដោះគោ | ១០ | ០ | ០ | ០ | ០ |
| ១៤ | ម្សៅទឹកដោះគោ | ០ | ៥ | ០ | ០ | ០ |
| សរុប | | **១០០** | ១០០ | ១០០ | ១០០ | ១០០ |

*(ប្រភព: USAID 2011: បច្ចេកទេសផ្សំចំណីជ្រូកដោយប្រើប្រាស់វត្ថុធាតុដើមក្នុងស្រុក)*

*បរិមាណចំណីឱ្យជ្រូកស៊ី (គិតតាម គ.ក ថ្ងៃ ក្បាល)*

| ល.រ | អាយុកាល(ថ្ងៃ) | បរិមាណ(គ.ក/ថ្ងៃ/ក្បាល) |
|---|---|---|
| ១ | ៣០ | ០.៣០ |
| ២ | ៤២ | ០.៥ |
| ៣ | ៦០ | ១ |
| ៤ | ៧០ | ១.៤ |
| ៥ | ៨២ | ១.៥ |
| ៦ | ៩៤ | ២ |
| ៧ | ១០៦ | ២.២ |
| ៨ | ១២០ | ២.៤ |
| ៩ | ១៣៣ | ២.៦ |
| ១០ | ១៤៥ | ២.៨ |
| ១១ | ១៥៨-២៧០ | ៣ |

*តម្រូវការទឹកប្រចាំថ្ងៃសម្រាប់ជ្រូក*

| ល.រ | ទម្ងន់ជ្រូកគិតជា គ.ក្រ | បរិមាណទឹកគិតជាលីត្រក្នុង១ថ្ងៃ |
|---|---|---|
| ១ | កូនផ្តាច់ដោះ | ២ |
| ២ | ១០-២៥ | ៤-៥ |
| ៣ | ២៦-៥០ | ៦ |
| ៤ | ៥១-៦៥ | ៨ |
| ៥ | ៦៦-១០០ | ១០ |
| ៦ | ១០១-១២០ | ១២ |
| ៧ | មេជើម | ១៥ |
| ៨ | មេជ្រូកបំបៅកូន | ២៥-៣០ |

*(ប្រភព:ដកស្រង់ចេញពីសៀវភៅបច្ចេកទេសកសិកម្មខេត្តព្រៃវែង ២០១១)*

## ឧបសម្ព័ន្ធ៣៖ ស្នូកទឹក និងចំណីសម្រាប់ជ្រូក

*<u>គម្រូស្នូកចំណី:</u>*

១- *<u>ស្នូករាងមូលសម្រាប់កូនជ្រូក</u>*

ស្នូកប្រភេទនេះ គេអាចផលិតចេញពីលោហៈក៏បាន ឬពីស៊ីម៉ងត៍ក៏បាន ដោយធ្វើឱ្យមានរាងមូល និងមានចំរឹងដែកខ័ណ្ឌចែកប្រឡោះតូចៗ ដែលមានទំហំល្មមអាចឱ្យកូនជ្រូកអាចស៊កក្បាលចូលស៊ីចំណីបាន (មើលរូប)។ ស្នូកប្រភេទនេះកសិករអាចធ្វើដោយខ្លួនឯងក៏បាន ឬទិញពីទីផ្សារក៏បាន។





២- *<u>ស្នូករាងជាចតុកោណព្នាយ</u>*

ស្នូកប្រភេទនេះគេអាចផលិតចេញពីឈើ ឬពីស៊ីម៉ងត៍ ដែលកសិករអាចធ្វើដោយខ្លួនឯង ហើយប្រើសំរាប់ដាក់ចំណីឱ្យជ្រូកធំៗ។





៣- *ស្នូកជាប់ជញ្ជាំងទ្រុង*

ស្នូកប្រភេទនេះធ្វើពីស៊ីម៉ងត៍ឱ្យជាប់ទៅនឹងជញ្ជាំង និងមានរន្ធបង្ហូរនៅក្រោជញ្ជាំងផ្នែកខាងក្រោមសម្រាប់លាងបង្ហូរកាកសំណល់ចោល។ ប្រើដាក់ចំណីឱ្យជ្រូកធំក៏បាន ជ្រូកតូចក៏បាន។ សម្រាប់ជ្រូកតូចគឺត្រូវមានចំរឹងដែកខ័ណ្ឌទទឹងស្នូក ដើម្បីចែកប្រឡោះឱ្យកូនជ្រូកស៊ីចំណីនិង ការពារវាពីការចូលដេកក្នុងស្នូក។ (មើលរូប)





*ស្នូកទឹក*

គេប្រើសម្ភារៈស្អាតដែលអាចដក់ទឹកបាន ដើម្បីដាក់ទឹកឱ្យសត្វជ្រូកផឹកដូចជាចានដែក និងឧបករណ៍ដូចស្នូកចំណីខាងលើជាដើម ឬតជាបណ្តាញទឹកដែលមានអាងស្តុកទឹកនៅទីខ្ពស់ និងក្បាលបឺតជាប់នឹងជញ្ជាំងឱ្យសត្វជ្រូកផឹកដោយខ្លួនឯង។ (មើលរូប)



ក្បាលបឺត



# ជំពូកទី ៥៖ ការថែទាំសុខភាពសត្វជ្រូក និងអនាម័យ

<u>រយៈពេល:</u> កន្លះថ្ងៃ

<u>គោលបំណង:</u>

- ឲ្យកសិករយល់ដឹងពីសារៈសំខាន់នៃការធ្វើអនាម័យ (ជីវសុវត្ថិភាព)
- ណែនាំកសិករឱ្យចេះពីវិធានការការពារ និងទប់ស្កាត់ជំងឺ

<u>សម្ភារៈ</u>

ក្រដាស់ផ្ទាំងធំ ហ្វឺត ស្កុត និងផ្ទាំងរូបភាព

**៤. ដំណើរការ**

**សកម្មភាពទី ១៖** ការការពារសុខភាព

១. បំផុសគំនិតកសិករអំពីវិធានការការពារ និង ជីវសុវត្ថិភាព

២. សរសេរចម្លើយរបស់ពួកគាត់ដាក់ក្នុងក្រដាសផ្ទាំងធំ រួចប្រៀបធៀបជាមួយចម្លើយក្នុងជំនួយស្មារតីខាងក្រោម៖

**ជំនួយស្មារតី៖ វិធានការការពារ  អនាម័យ និងជីវសុវត្ថិភាព**

- ឧស្សាហ៍ធ្វើអនាម័យទ្រុងឱ្យបានញឹកញាប់ (២ ទៅ ៣ដងក្នុង១ថ្ងៃ)
- សំអាតស្នូកទឹកស្នូកចំណីជាប្រចាំ
- ផ្តល់ចំណីនិងទឹកស្អាតដល់ជ្រូកឲ្យបានគ្រប់គ្រាន់
- បង្ការកុំឲ្យសត្វផ្សេងៗទៀតចេញចូលក្នុងទ្រុងជ្រូក (ដូចជា ឆ្កែ កណ្តុរ...)
- ហាមអ្នកដទៃចេញ-ចូលក្នុងទ្រុងជ្រូក ឬធ្វើការផ្លាស់ប្តូរសំលៀកបំពាក់ និងសំលាប់មេរោគលើស្បែកជើងជាមុន មុននឹងអនុញ្ញាតឱ្យចូលទ្រុងជ្រូក
- ត្រូវមានកន្លែងសម្រាប់ដាក់ថ្នាំសម្លាប់មេរោគមុនចេញ-ចូលក្នុងទ្រុងជ្រូក
- ធ្វើការសំអាតសំលាប់មេរោគលើសម្ភារៈផ្សេងៗដែលត្រូវយកមកប្រើប្រាស់ចិញ្ចឹមជ្រូកជាមុនមុននឹងប្រើប្រាស់វា
- ត្រូវសង់ទ្រុងជ្រូកឱ្យដាច់ពីលំនៅឋាន និងឆ្ងាយពីទ្រុង ឬក្រោលសត្វផ្សេងៗទៀត (កុំចិញ្ចឹមសត្វ ឡូកឡំគ្នាក្នុងទ្រុងតែមួយ)
- សំលាប់មេរោគលើទ្រុងជ្រូកនិងសម្ភារៈចិញ្ចឹមផ្សេងៗទៀតដោយប្រើកំបោរស ឬទឹកកំបោរស
- ចិញ្ចឹមសត្វទៅតាមប្រភេទ អាយុឲ្យដាច់ដោយឡែកពីគ្នា
- បង្ខាំងជ្រូកដែលទើបនឹងយកមកដល់ថ្មីដាច់ដោយឡែកពីគេឯង
- បំបែកជ្រូកឈឺចេញពីជ្រូកជា

- ជ្រូកឈឺ ឬងាប់ដោយជំងឺត្រូវកប់ ឬដុតចោល
- ជ្រូកឈឺ ឬងាប់ដោយជំងឺ មិនត្រូវបរិភោគ ឬចែកចាយ ឬលក់ដូរ...
- ត្រូវចាក់វ៉ាក់សាំងការពារសត្វឱ្យបានទៀងទាត់ (មើលកម្មវិធីធ្វើវ៉ាក់សាំងទំព័រទី៥៦-៥៧)

# ជំពូកទី ៦៖ ជំងឺសំខាន់ៗរបស់ជ្រូក និងការព្យាបាល

<u>រយៈពេល:</u> ២ថ្ងៃ

<u>គោលបំណង:</u>

- ឱ្យកសិករយល់ដឹងពីរោគសញ្ញានៃជំងឺសំខាន់ៗដែលប៉ះពាល់ដល់ជ្រូក
- ណែនាំកសិករឱ្យចេះការពារទប់ស្កាត់ ព្យាបាល និងការថែទាំជ្រូក

<u>សម្ភារៈ</u>

ក្រដាស់ផ្ទាំងធំ ហ្វឺត ស្កុត រូបភាព ឯកសារមេរៀន និងឧបសម្ព័ន្ធ១,២និង៣

<u>ដំណើរការ:</u>

សកម្មភាព១៖ ផលប៉ះពាល់នៃជំងឺលើសត្វជ្រូក

១. សួរកសិករថាតើការចិញ្ចឹមជ្រូកន្លងមកមានជួបបញ្ហាជ្រូកឈឺដែរ ឬទេ?

២. តើវាមានផលប៉ះពាល់អ្វីខ្លះនៅពេលដែលជ្រូកឈឺ?

៣. កត់ត្រាចម្លើយរបស់គាត់ដាក់ចូលក្នុងក្រាដាស់ផ្ទាំងធំ

៤. ពិភាក្សាចម្លើយ និងពិនិត្យមើលជំនួយស្មារតីខាងក្រោម

| ជំនួយស្មារតី: ផលប៉ះពាល់នៃជំងឺលើសត្វជ្រូក |
|---|
| - ផលិតកម្មធ្លាក់ចុះ ចំនួនជ្រូកឈឺ និងងាប់ច្រើន<br>- ឆ្លងជម្ងឺដល់ជ្រូក និងសត្វដ៏ទៃទៀត<br>- ប៉ះពាល់ដល់សុខភាពមនុស្ស(អ្នកចិញ្ចឹមអ្នកលក់ និងអ្នកទិញ)<br>- ចំណាយថវិកាច្រើន និងធ្វើឱ្យបាត់បង់ប្រាក់ចំណូល<br>- ការចិញ្ចឹមត្រូវបានផ្អាក ឬហាមឃាត់មួយរយៈនៅក្នុងតំបន់ផ្ទុះជំងឺ<br>- ប៉ះពាល់ចរាចរណ៍សត្វ និងការលក់ដូរនៅក្នុងតំបន់មូលដ្ឋាន<br>- ប៉ះពាល់ដល់សេដ្ឋកិច្ចគ្រួសារ និងជាតិ |

**សកម្មភាព២៖** ជម្ងឺសំខាន់ៗរបស់ជ្រូក

១. ឱ្យកសិករៀបរាប់ឈ្មោះជំងឺជ្រូកដែលគាត់ជួបប្រទះក្នុងការចិញ្ចឹម

២. កត់ត្រាចម្លើយរបស់គាត់ដាក់ចូលក្នុងក្រដាស់ផ្ទាំងធំ

៣. ផ្តល់ចម្លើយនៅក្នុងឯកសារចែកជូន(ឧបសម្ព័ន្ធ១និង២) ហើយធ្វើការប្រៀបធៀបចម្លើយជាមួយ និងកសិករ

**សកម្មភាព៣៖** ការការពារ និងទប់ស្កាត់ជំងឺ

១. សួរកសិករថាតើគាត់មានវិធានការអ្វីខ្លះមុន និងក្រោយពេលផ្ទុះជំងឺ

២. កត់ត្រាចម្លើយរបស់គាត់ដាក់ក្នុងក្រដាសផ្ទាំងធំ

៣. ពន្យល់កសិករអំពីសារៈសំខាន់នៃការការពារ និងទប់ស្កាត់ជំងឺ (ជីវសុវត្ថិភាព)

៤. មើលឧបសម្ព័ន្ធ៣ដើម្បីពន្យល់បន្ថែម

## ឧបសម្ព័ន្ធ១៖ ជម្ងឺសំខាន់ៗរបស់សត្វជ្រូក

*ក-ជម្ងឺឆ្លងរាតត្បាត*

*១- <u>ជំងឺប៉េស្ត</u>*

ជាប្រភេទជម្ងឺបង្កឡើងដោយវីរុសដែលឆ្លងរាលដាលយ៉ាងខ្លាំង និងបណ្តាលឲ្យជ្រូកឈឺ ព្រមទាំងងាប់យ៉ាងច្រើន ពិសេសកូនជ្រូក។

<u>ការចម្លងជំងឺ</u>

- តាមរយៈចំណីអាហារ ទឹក ឬឧបករណ៍ កាកសំណល់ដែលប្រឡាក់ប្រឡូកដោយមេរោគ
- ប៉ះពាល់ផ្ទាល់រវាងសត្វឈឺ និងសត្វជា
- តាមផ្លូវរំលាយអាហារ និងផ្លូវដង្ហើម
- តាមរយៈការបង្កាត់ពូជ

<u>រោគសញ្ញាទូទៅ:</u>

- ជ្រូកមានអាការៈស្រងូតស្រងាត់រយៈពេល៣ទៅ៥ថ្ងៃ
- កំដៅឡើងដល់៤០-៤២ អង្សារសេ
- ជ្រូកអត់ស៊ីចំណី ក្អួត ភ្នែកក្រហម ហើយមានពពឹកភ្នែកខាប់ និងទឹកភ្នែកហៀរផងដែរ
- គ្មៀន ទល់លាមក ក្រោយមករាគរូសយ៉ាងខ្លាំង លាមកស្អុយខ្លាំង
- ជ្រូកហាក់ដូចជារងារ នៅជ្រៀតជុំគ្នា មានខ្លះអង្គុយដូចឆ្កែពិបាកដកដង្ហើម គេឃើញមានសញ្ញាខាងសរសៃប្រសាទ ដើរពាន់ជើង ហើយប្រកាច់
- មេជ្រូករលូតកូន
- មានស្នាមជាំក្រហមលើខ្លួន (សំខាន់នៅចន្លោះភ្លៅទាំងពីរនិងនៅលើពោះ)
- កំដៅចាប់ផ្តើមធ្លាក់ចុះមានការស្រៀវស្រាញហើយងាប់ច្រើន

<u>ការការពារ និងព្យាបាល:</u>

<u>ការការពារ</u>

- ចាក់វ៉ាក់សាំងឱ្យបានទៀតទាត់
- ធ្វើអនាម័យទ្រុង និងខ្លួនជ្រូកឱ្យបានស្អាតជាប្រចាំអនាម័យទ្រុង
- បំបែកជ្រូឈឺចេញពីជ្រូកជា
- កប់សាកសពសត្វឲ្យបានត្រឹមត្រូវតាមវិធានការណ៍របស់បសុពេទ្យ

<u>ការព្យាបាល</u>

គ្មានថ្នាំព្យាបាលទេ ព្រោះជំងឺនេះវាបង្កឡើងដោយវីរុស

## ២- *ជំងឺសារទឹកជ្រូក*

ជាជំងឺដែលបង្កឡើងដោយបាក់តេរី ហើយវាជាជំងឺឆ្លងលើជ្រូកគ្រប់ប្រភេទ និងគ្រប់រដូវកាល ជាពិសេសពេលមានអាកាសធាតុប្រែប្រួល និងសុខភាពសត្វចុះខ្សោយ។

ការចម្លងជំងឺ:

- តាមរយៈ ទឹកមាត់ និង ទឹកសំបោរដែលមានមេរោគ
- លាមកសត្វឈឺដែលប្រឡាក់ប្រឡូកជាមួយនឹងចំណី និងទឹក (ស្នូកទឹក ស្នូកចំណី)
- ប៉ះពាល់ផ្ទាល់ជាមួយជ្រូកឈឺ

រោគសញ្ញា:

- ស៊ីចំណីតិចខ្សោយអស់កំលាំងហើយងងុយដេកខ្លាំង
- កំដៅឡើងដល់៤០-៤២អង្សារសេហើយវាផឹកទឹកច្រើន
- ហើមបំពង់ក កន្លែងហើមឡើងក្តៅ និងមានការឈឺចាប់ ពិបាកដកដង្ហើម (ដង្ហក់) ដកដង្ហើមឮសូរឃ្យូសៗ ក្អក
- ក្អួតហើយរួញខ្លួនពេលក្អកម្តងៗ
- ហៀរទឹកមាត់ និងទឹកសំបោរខាប់
- មានចំនុចក្រហមឬផ្ទាំងពណ៌ខៀវនៅលើកទ្រូងពោះ និងកៀនភ្លៅ
- ដំបូងលាមករឹងក្រោយមករាគនិងមានលាយឈាម
- ហើមគន្លាក់ជើង
- ស្បែកក្រហមជួនកាលមានរបកផ្ទាំងៗ
- ជ្រូកងាប់:
  - ករណីធ្ងន់ធ្ងរ ពី ១ទៅ ២ថ្ងៃ
  - មធ្យម ពី ៣ ទៅ ១០ថ្ងៃ
  - ស្រាល ពី ៥ ទៅ ៦សប្តាហ៍

វិធីសាស្រ្តការពារនិងការព្យាបាល

ការការពារ

សម្អាតសម្ភារៈចិញ្ចឹមជ្រូកជាពិសេសឧបករណ៍ដែលប្រើសម្រាប់ដាក់ទឹក និងចំណីជ្រូក។

- ធ្វើអនាម័យទ្រុង
- ចាក់វ៉ាក់សាំងឱ្យបានទៀតទាត់គឺនៅដើមរដូវភ្លៀង(រឺចុងរដូវប្រាំង)និងចុងរដូវភ្លៀង

ការព្យាបាល

- ប្រើថ្នាំក្រុមស៊ុលហ្វាមីដ(ស៊ុលហ្វាមេរ៉ាស៊ីន និងស៊ុលហ្វាមេតាស៊ីន)ឱ្យជ្រូកផឹកឬចាក់
- ចាក់ប្រភេទថ្នាំអង់ទីប៊ីយ៉ូទីក ឬអុកស៊ីតេត្រាស៊ីគ្លីន ឬអាល់ប៊ីប៉ែន ប្រើរយៈពេល៣-៥ថ្ងៃ។

៣- *ជម្ងឺកញ្រ្ជិល:*

ជាជំងឺដែលបង្កឡើងដោយបាក់តេរី ហើយវាឆ្លងជាពិសេសលើជ្រូកមិនទាន់ពេញវ័យ។

ការចម្លង

- ចំណីអាហារ ទឹក ដែលប្រឡាក់ប្រឡូកដោយលាមក និងកាកសំណល់ដែលមានមេរោគ
- តាមការប៉ះពាល់មុខរបួសជាមួយសត្វឈឺ

រោគសញ្ញា:

- ឡើងកំដៅពី ៤០-៤២អង្សាសេ
- សត្វមិនស៊ីចំណីស្រងូតស្រងាត់ ដេកថ្ងូរ
- មានស្នាមក្រហមលើស្បែក ស្បែកស្ងួត និងរបកក្រមរទាំងផ្ទាំង
- ភ្នែកឡើងក្រហម
- លាមកពណ៌ខ្មៅដុំ និងមានសំបោរព័ទ្ធជុំវិញ
- រលាកសន្លាក់ និងខ្វើចជើង
- ពិបាកដកដង្ហើមនិងហៀរសំបោរ ហើយក្អក
- នៅលើខ្នង ពោះ ក្បាល ស្មា ច្រមុះ ត្រចៀកហើមក្រហមទាំងផ្ទាំងៗដែលអាចរលាកចេញទឹកស្អុយរលួយ។
- អាចងាប់ពី៥០ទៅ៦០%

ការការពារនិងព្យាបាល

ការការពារ

- អនាម័យទ្រុង សម្ភារៈប្រើប្រាស់ផ្សេងៗ និងវិធានការជីវសុវត្ថិភាព
- ចាក់វ៉ាក់សាំងឱ្យបានទៀងទាត់

ការព្យាបាល

- ចាក់ថ្នាំប៉េនីស៊ីលីន ឬអាមុកស៊ីលីនព្យាបាលរយៈពេលពី ៣ទៅ ៥ថ្ងៃ
- អាចប្រើទឹកសាប៊ូ លាយសាប៊ូជាមួយទឹកក្តៅអ៊ុនៗ រួចយកក្រណាត់ជ្រលក់ទឹកសាប៊ូនេះ ហើយជូតឲ្យសព្វលើខ្លួនជ្រូក

៤- *ជំងឺត្រចៀកខៀវជ្រូក (PRRS)*

ជាប្រភេទជម្ងឺបង្កឡើងដោយវីរុសដែលឆ្លង និងរាលដាលយ៉ាងខ្លាំង។ កើតឡើងលើជ្រូកគ្រប់វ័យ។ សកម្មភាពបង្ករោគនៅលើប្រដាប់បន្តពូជ និងលើប្រដាប់ផ្លូវដង្ហើម។

ការចម្លងជំងឺ
- តាមរយៈចំណីអាហារ ទឹក ឬឧបករណ៍ កាកសំណល់ដែលប្រឡាក់ប្រឡូកដោយមេរោគ
- ប៉ះពាល់ផ្ទាល់រវាងសត្វឈឺ និងសត្វជា
- តាមផ្លូវរំលាយអាហារ និងផ្លូវដង្ហើម
- តាមរយៈការបង្កាត់ពូជ

រោគសញ្ញាទូទៅ:
- កំដៅឡើងដល់៣៩-៤០ អង្សារសេ
- មិនសូវស៊ីចំណី និងផឹកទឹក
- មេជ្រូករលូតកូន កូនងាប់ក្នុងពោះ កូនធំមិនស្មើគ្នា ឬកូនកើតមុនថ្ងៃកំណត់ កូនខ្សោយ និងមេមិនមានទឹកដោះ
- ការបង្កាត់ពូជថយចុះ
- ការបង្កកំណើតតិច
- រលាកសួតធ្ងន់ធ្ងរ ក្អក ពិបាកដកដង្ហើម និងហូរទឹកភ្នែក (កូនជ្រូក)
- មានស្នាមជាំក្រហមលើខ្លួន រោមបះ
- ត្រចៀកប្រែពណ៌ឡើងជាំខៀវ

ការការពារ និងព្យាបាលៈ

ការការពារ
- ធ្វើអនាម័យទ្រុង និងខ្លួនជ្រូកឱ្យបានស្អាតជាប្រចាំអនាម័យទ្រុង
- បំបែកជ្រូឈឺចេញពីជ្រូកជា
- កប់សាកសពសត្វឲ្យបានត្រឹមត្រូវតាមវិធានការណ៍របស់បសុពេទ្យ

ការព្យាបាល
ប្រើថ្នាំអង់ទីប្យូទីកដើម្បីទប់ស្កាត់មេរោគឱកាសនិយម

*៥- ជំងឺអូហេស្គី*

ជាជំងឺដែលបង្កឡើងដោយវីរុស ហើយអាចបង្កគ្រោះថ្នាក់ធ្ងន់ធ្ងរលើកូនជ្រូកជាងជ្រូកធំ។

រោគសញ្ញា
- កូនជ្រូកក្អួត ញាក់ញ័រ កន្ត្រាក់ខ្លួន ធាក់ជើងខ្វែៗ
- ប្រកាច់ដោយសារមេរោគរាតត្បាតលើប្រព័ន្ធប្រសាទ
- ហើមភ្នែក ឬគ្រាប់ភ្នែកលៀន រឹងថ្លាម

- រលូតកូន ឬងាប់កូនក្នុងពោះ
- អត្រាងាប់ខ្ពស់

<u>ការការពារ និងព្យាបាល</u>

<u>ការការពារ</u>

- ធ្វើអនាម័យទ្រុង និងខ្លួនជ្រូកឱ្យបានស្អាតជាប្រចាំអនាម័យទ្រុង
- បំបែកជ្រូលឈឺចេញពីជ្រូកជា
- កប់សាកសពសត្វឲ្យបានត្រឹមត្រូវតាមវិធានការណ៍របស់បសុពេទ្យ

<u>ការព្យាបាល</u>

គ្មានថ្នាំព្យាបាល ប៉ុន្តែប្រើអង់ទីប្យូទីក ដូចជា៖ អំពីសាលីន អាម៉ុកស៊ីលីន ...ដើម្បីទប់ស្កាត់មេរោគឱកាសនិយម។

*៦- ជំងឺអុតក្តាម*

ជំងឺអុតក្តាមជាជំងឺឆ្លងរាលដាលយ៉ាងឆាប់រហ័ស ហើយមានសភាពធ្ងន់ធ្ងរ។ ជំងឺនេះកើត ចំពោះសត្វដែលមានក្រចកជើង ច្រវែកដូចជា គោ ក្របី ពពែ ចៀម និងជ្រូក។ ជំងឺអុតក្តាមបង្កឡើងដោយវីរុស។

<u>ការចម្លងជំងឺ:</u>

សត្វដែលមានជំងឺអុតក្តាមបានបញ្ចេញមេរោគនេះតាមរយៈទឹកមាត់ ទឹកដោះគោ លាមក និង ទឹកនោម។ ការចម្លងជំងឺអុតក្តាមនេះតាមរយៈ

- តាមរយៈខ្យល់ដកដង្ហើម
- ការប៉ះពាល់ដោយផ្ទាល់រវាងសត្វឈឺ និង សត្វ ឬ
- តាមរយៈទឹកមាត់ ទឹកដោះគោ លាមក និង ទឹកនោមដែលមានមេរោគ
- តាមរយៈសម្ភារៈប្រើប្រាស់ដែលមានមេរោគ
- តាមរយៈសំលៀកបំពាក់ ស្បែកជើងដែលមានមេរោគ

<u>រោគសញ្ញា:</u>

- ជ្រូកហេវហត់ មិនស៊ីចំណី និង គ្រុនក្តៅ
- ជើងសត្វមានសភាពឈឺចាប់ និង ស្ពឹកស្រពន់ មិនអាចផ្លាស់ទីបាន
- កំដៅក្នុងខ្លួនឡើងដល់ ៤១-៤២ អង្សាសេ
- មានពងបែកថ្លានៅលើមាត់ ច្រមុះ ក្រចកជើង កន្សោមដោះ ចុងដោះ។ ប៉ុន្តែចំពោះជ្រូកគេមិនសូវជួបប្រទះ ពងបែកដែលមាននៅលើអណ្តាត។

- មេដើមបណ្ដាលឱ្យរលូត
- កូនកំពុងបៅដោះបណ្ដាលឱ្យងាប់លឿន និងសត្វងាប់ដោយស៊ីចំណីមិនកើត

<u>ការការពារ និងការព្យាបាល</u>

<u>ការការពារ:</u>

វិធានការល្អបំផុតគឺត្រូវចាក់វ៉ាក់សាំងឱ្យបាន ២ ដង ក្នុង ១ ឆ្នាំ។

- ចំពោះកូនជ្រូកដែលកើតពីមេ បា ដែលបានចាក់វ៉ាក់សាំង ត្រូវចាក់វ៉ាក់សាំងនៅអាយុ ៦០ ថ្ងៃ និង ចាក់លើកទី ២ នៅ ២៨ ថ្ងៃក្រោយពីការចាក់លើកទី ១។
- ចំពោះកូនជ្រូកដែលកើតពីមេបាដែលមិនបានចាក់វ៉ាក់សាំងត្រូវចាក់វ៉ាក់សាំងនេះនៅអាយុ ១៥ ថ្ងៃ និងចាក់លើកទី ២ នៅ ២៨ ថ្ងៃ ក្រោយពីចាក់លើកទី ១។
- ត្រូវរំលឹករៀងរាល់ ៦ ខែ ម្ដង។

<u>ការព្យាបាល:</u>

ជំងឺអុតក្ដាមមិនមានថ្នាំព្យាបាលទេប៉ុន្តែគេអាចប្រើអង់ទីប៊ីយ៉ូទិកមួយចំនួនដើម្បីការពារ ការជ្រៀតចូលមេរោគឱកាសនិយមផ្សេងៗទៀត ឬ ដើម្បីព្យាបាលដំបៅ:

- ប្រើថ្នាំទ្រីមេតូព្រីម ជាមួយស៊ុលហ្វា ឬអុកស៊ីតេត្រាស៊ីគ្លីន ប្រើរយៈពេល ៥ ទៅ ៧ថ្ងៃ
- លាងដំបៅជាមួយនឹងទឹកម្ជូរ ឬសាប៊ូ
- បាញ់ថ្នាំពណ៌ខៀវដែលមានអុកស៊ីតេត្រាស៊ីគ្លីន
- ដាក់សត្វឈឺនៅកន្លែងស្ងួត

*៧- <u>ជំងឺរាគកូនជ្រូក:</u>*

ជំងឺរាគកូនជ្រូកបណ្ដាលមកពីកត្តាច្រើនយ៉ាង។ វិធានការការពារ និងការគ្រប់គ្រងជំងឺ មិនគួរផ្ដោតលើការឆ្លងដោយមេរោគ ឬចំណីប៉ុណ្ណោះទេ តែវាបណ្ដាលមកពីកត្តាអាកាសធាតុផងដែរ។

<u>ការចម្លង</u>

- បណ្ដាលមកពីចំណីអាហារ
- មកពីអាកាសធាតុប្រែប្រួល
- ខ្វះសារធាតុរ៉ែក្នុងចំណី (ដែក ទង់ដែង ....)
- មេជ្រូកមានជំងឺ រលាកស្បូន និងលាសដោះ

ជំងឺរាគបណ្ដាលមកពី អឺកូលី

រោគសញ្ញា

- មានរយៈពេល៥-៧ថ្ងៃ
- លាមកជាប់គូទពណ៌លឿង ភាគច្រើនមានក្លិនស្អុយ
- ខ្សោះជាតិទឹក ស្គមស្លេកស្លាំង និងស្រកទម្ងន់យ៉ាងលឿន

ការការពារ និងព្យាបាល

ការការពារ

- ឲ្យជ្រូកបៅទឹកដោះដំបូង
- កុំឲ្យកូនជ្រូករងារ និងត្រូវខ្យល់ខ្លាំង
- ផ្ដល់កំដៅកូនជ្រូកទើបនឹងកើតឲ្យបានគ្រប់គ្រាន់
- ត្រូវផ្ដល់ជាតិដែកដល់កូនជ្រូកឲ្យបានគ្រប់គ្រាន់
- ទ្រុងជ្រូកត្រូវតែស្ងួត មានពន្លឺថ្ងៃគ្រប់គ្រាន់ និងមានខ្យល់ចេញចូលល្អ

ការព្យាបាល

**ចំពោះមេ**

- ប្រើថ្នាំទ្រីម៉េតូព្រីមជាមួយនឹងស៊ុលហ្វា ចាក់សាច់ដុំម្ដងក្នុង១ថ្ងៃក្នុងរយៈពេល៣ថ្ងៃ

**ចំពោះកូន**

- ប្រើថ្នាំកូលីស្ទីនជាមួយអំពីសេលីន ចាក់សាច់ដុំម្ដងក្នុង១ថ្ងៃរហូតដល់ជាសះស្បើយ(ពី ៣ទៅ ៥ថ្ងៃ)

បណ្ដាលមកពីកុកស៊ីដ្យូស៊ីស

វាកើតឡើងលើកូនជ្រូក ពីថ្ងៃ ៧ទៅ ២១ថ្ងៃ

រោគសញ្ញា

- រាគពណ៌លឿងទៅជាពណ៌ប្រផេះ បៃតង
- លាមកមានសភាពដូចក្រែម និងម្សៅ
- កូនជ្រូកស្គម ជ្រីវជ្រួញខុសពីធម្មតា

ការការពារ និងព្យាបាល

ការការពារ

បញ្ចាក់ថ្នាំ តុលត្រាស៊ូរីល (អង់ទីកុក បៃកុក) ឲ្យកូនជ្រូកទើបកើតបាន៣ថ្ងៃ

ខ. ការព្យាបាល

ប្រើថ្នាំស៊ុលហ្វា(ស៊ុលហ្វា៣៣ សិបតូទ្រីល) ប្រើរយៈពេលពី ៣ទៅ៥ថ្ងៃ

បណ្ដាលមកពីក្លូស៊ីឌីដ្យូម (រាគឈាម)

រោគសញ្ញា

- កូនជ្រូករាគខ្លាំងមានលាយឈាម មានក្លិនស្អុយ
- កើតលើកូនជ្រូកពី ១ទៅ ៧ថ្ងៃ
- អត្រាងាប់ខ្ពស់
- ច្រើនកើតលើកូនជ្រូកដែលដើរពាសវាលពាសកាល

ការការពារនិងព្យាបាល

ការការពារ

- អនាម័យទ្រុង សម្ភារៈប្រើប្រាស់ផ្សេងៗ និងវិធានការជីវសុវត្ថិភាព
- ឲ្យជ្រូកបៅទឹកដោះដំបូង
- កុំឲ្យកូនជ្រូករងារ និងត្រូវខ្យល់ខ្លាំង
- ផ្ដល់កំដៅកូនជ្រូកទើបនឹងកើតឲ្យបានគ្រប់គ្រាន់
- ត្រូវផ្ដល់ជាតិដែកដល់កូនជ្រូកឲ្យបានគ្រប់គ្រាន់
- ទ្រុងជ្រូកត្រូវតែស្ងួត មានពន្លឺថ្ងៃគ្រប់គ្រាន់ និងមានខ្យល់ចេញចូលល្អ

ការព្យាបាល

បញ្ចាក់អាម៉ុកស៊ីលីន

៨- *ជម្ងឺរលាកផ្ចិតកូនជ្រូក:*

បណ្ដាលមកពីការកាត់ទងផ្ចិតនិងការលាបថ្នាំការពារមិនបានត្រឹមត្រូវ។

រោគសញ្ញា:

- ផ្ចិតឡើងធំ ទងផ្ចិតក្រហម ក្ដៅ
- ពេលប៉ះវាត្រង់ផ្ចិតកូនជ្រូកស្រែកញ័រខ្លួនហើយមានសរសៃប៉ោងក្រោមពោះ
- ឡើងកំដៅស្រងូតស្រងាត់មិនបៅ
- ដង្ហើមញាប់ រាគស្គម-ស្បែកជ្រីវជ្រួញ
- ស្បែកស្ងួត រោមបះ

- បើរាគយូរកូនជ្រូកនឹងហើមសន្លាក់ ពិបាកដើរ ល្វើយផ្ចិត និងមានទឹកលឿង ក្រមៅហូរចេញពីរន្ធផ្ចិត (មានក្លិនស្អុយ)

<u>ការការពារ និងការព្យាបាល</u>

<u>ការការពារ</u>

កាត់ទងផ្ចិត និងលាបថ្នាំការពារឲ្យបានត្រឹមត្រូវតាមបច្ចេកទេស

<u>ការព្យាបាលៈ</u>

-ដាំទឹកឱ្យពុះហើយទុកឱ្យត្រជាក់រួចលាយជាមួយPermanganate de potassium (១ក្រាមលាយជាមួយទឹក១លីត្រ)

ប្រើទឹកអំបិលលាងសំអាតផ្ចិត ហើយទុកឱ្យស្ងួតទើបលាបថ្នាំក្រហមរួចរោយម្សៅថ្នាំស៊ុលហ្វាមីដពីលើផ្ចិត

-ចាក់ប៉េនីស៊ីលីនជុំវិញផ្ចិតនិងចាក់សាច់ដុំរយៈពេល៣-៤ថ្ងៃ

*៩- <u>ជំងឺដែលបង្កឡើងដោយប៉ារ៉ាស៊ីត</u>*

ប៉ារ៉ាស៊ីតជាសត្វល្អិតតូចៗដែលរស់នៅខាងក្នុងខ្លួនសត្វ ដែលរស់នៅដោយសាគេ និងបំផ្លាញគេ។ វាចិញ្ចឹមជីវិតដោយការបឺតជញ្ជក់ និងសារធាតុចិញ្ចឹមពីសត្វដែលវាស្នាក់អាស្រ័យជាមួយ ធ្វើឲ្យសត្វស្គម ខ្សោយ ងាយទទួលជំងឺ ករណីធ្ងន់ធ្ងរអាចងាប់បាន។ប៉ារ៉ាស៊ីតមានពីរប្រភេទគឺ ប៉ារ៉ាស៊ីតខាងក្រៅ និង ប៉ារ៉ាស៊ីតខាងក្នុង។

**<u>១. ប៉ារាស៊ីតក្រៅ</u>**

ពពួកប៉ារ៉ាស៊ីតខាងក្រៅ រស់នៅលើស្បែកសត្វ ឬ ក្រោមស្បែកសត្វ។ វាធ្វើឱ្យសត្វ រមាស់នៅមិនស្ងៀម អេះច្រើន ចុះស្គម ជួនកាលវាធ្វើឱ្យស្បែកឡើងក្រម៉ រ។ ប៉ារ៉ាស៊ីតខ្លះទៀត ដូចជា ចៃ ឬ ដង្កែ ខាំជញ្ជក់ឈាមពីសត្វ ដែលធ្វើឱ្យសត្វអេះក្លាយទៅជារមាស់។

<u>រោគសញ្ញាៈ</u>

- សត្វចុះ ស្គម
- ការលូតលាស់យឺត
- ស្បែកជ្រីវជ្រួញ រោមស្រអាប់
- មានដំបៅរមាស់
- ជួនរាគ ជួនក្អៀន មានសភាពស្លេកស្លាំង

ការការពារ និងការព្យាបាលៈ

ការការពារ

- ធ្វើអនាម័យទ្រុង និងខ្លួនជ្រូកឱ្យបានស្អាតជាប្រចាំ
- បំបែកជ្រូកឈឺចេញពីជ្រូកជា
- ផ្តល់ចំណី និងទឹកស្អាត និងដាក់មុង

ការព្យាបាលៈ

- អ៊ីវ៉ូម៉ិចស៊ុបភើៈ ១ សេសេ សម្រាប់ទម្ងន់ ៣៣ គ.ក្រ គឺចាក់សើស្បែក។
- ប្រើអាស៊ីនតុល១ស្លាបព្រាកាហ្វេ (០.៥ក្រាម) លាយជាមួយទឹកកន្លះលីត្រ ហើយក្រឡុកវាឲ្យស្មើសាច់ រួចបាញ់លើខ្លួនសត្វ។
- ប្រើប៊ុយតុកៈ ១សេសេ លាយជាមួយទឹក ១លីត្រ រួចបាញ់លើខ្លួនសត្វភ្លាមបន្ទាប់ពីលាយរួច (ប្រសិទ្ធភាពរបស់វាមានរយៈពេល ១ ខែ)

## ២. ប៉ារ៉ាស៊ីតខាងក្នុងៈ

ភាគច្រើននៃប៉ារ៉ាស៊ីតខាងក្នុងគឺជាពពួកព្រូនដែលជាព្រូនមូល សំប៉ែត អៀន តេនញ៉ា។ល។ ប៉ារ៉ាស៊ីតខាងក្នុងរស់នៅកន្លែងខុសៗគ្នា ដូចជានៅក្នុងក្រពះ ពោះវៀន ថ្លើម សួត សាច់ដុំ ។ល។ ចំណីអាហារ ដែលសត្វស៊ីដើម្បីយកទៅចិញ្ចឹមសរីរាង្គកាយ មួយភាគធំនៃចំណីអាហារត្រូវបានស្រូបយកដោយពួកប៉ារ៉ាស៊ីត ដែលធ្វើឱ្យសត្វចុះស្គម ការលូតលាស់យឺត រោមស្រអាប់ហើយបះៗ សត្វមានសភាពស្លេកស្លាំងដែលជាហេតុនាំឱ្យសត្វងាយទទួលរងជំងឺផ្សេងៗ។ ក្នុងករណីដែលព្រូនមានចំនួនច្រើនអាចបណ្តាលឱ្យសត្វស្លាប់បាន។

រោគសញ្ញា

- ជ្រូកចុះស្គម ខ្សោយ ក្រិនក្រធំ លូតលាស់យឺត
- ជ្រូកក្អក រាគ ឬ ក្អួតចេញព្រូន
- រោមស្រអាប់ និងបះៗ
- ស្លេកស្លាំង

ការការពារនិងព្យាបាល

ការការពារ

- បញ្ចុះព្រូនឲ្យបានត្រឹមត្រូវតាមកម្មវិធី
- លាងបន្លែដែលត្រូវឱ្យស៊ីឱ្យបានស្អាត
- លាងសំអាតទ្រុងជាប្រចាំ
- មេបង់ដាសូលៈ ប្រើ១គ្រាប់ក្នុងទម្ងន់១០គីឡូក្រាមនៃទម្ងន់ជ្រូករស់ ប្រើរយៈពេល ១ ថ្ងៃ

*ការព្យាបាល:*

- អ៊ីវ៉ូម៉ិចស៊ីបភើ: ១ សេសេ សម្រាប់ទម្ងន់ ៣៣ គ.ក្រ គឺចាក់សើស្បែក។
- ឡេវ៉ាមីសូល:ចាក់សាច់ដុំ ១សេសេ ក្នុងទម្ងន់១០គីឡូក្រាមនៃទម្ងន់ជ្រូករស់ **(ហាមប្រើក្នុងពេលជាមួយនឹងថ្នាំសម្លាប់ប៉ារ៉ាស៊ីតខាងក្រៅ)**
- មេបង់ដាសូល: ប្រើ១គ្រាប់ក្នុងទម្ងន់១០គីឡូក្រាមនៃទម្ងន់ជ្រូករស់ ប្រើរយៈពេល ៣ ថ្ងៃ
- គេក៏អាចប្រើស្លាខ្ចីដោយកិនវាឱ្យជ្រូកស៊ីទៅតាមជ្រូកតូច ឬធំ

*១០-ជម្ងឺរបស់មេជ្រូក*

*ជម្ងឺរលូតកូន:*

កើតមានគ្រប់ខែ គ្រប់រដូវ បណ្តាលឱ្យកូនជ្រូកងាប់ ឬរស់ទាំងល្ងាក់ល្ងើរ។ ជម្ងឺរលូតកូននេះ អាចបណ្តាលមកពី:

- ដោយការប៉ះទង្គិច ដួល ឬហេរហត់ខ្លាំងនៅពេលផើម
- បណ្តាលមកពីចំណីខ្វះជីវជាតិ និង ស៊ីមិនគ្រប់គ្រាន់ ជាពិសេសកង្វះវីតាមីន A និង E កង្វះជាតិសាច់ ហើយវាច្រើនកើតលើមេជ្រូកកូនដំបូង
- មេជ្រូកស៊ីប៉ះចំណីដែលមានជាតិពុល
- ដោយសារការប្រើប្រាស់ឱសថមិនត្រឹមត្រូវតាមបច្ចេកទេស
- បណ្តាលមកពីមេរោគប្រភេទ ប្រ៊ូសេឡូស និងលិបតូស្ពៀរ៉ូស ដែលទាមទារឱ្យមានអន្តរាគមន៍ពីមន្ត្រីផលិតកម្ម និងបសុព្យាបាល។
- បណ្តាលមកពីជំងឺមួយចំនួនទៀតដូចជា៖ ជំងឺអូយេស្គី ត្រចៀកខៀវ ប៉េស្ត ប្រ៊ូសេឡូស៊ីស និងលិបតូស្ពៀរ៉ូស៊ីស

<u>រោគសញ្ញា</u>

- ខ្លួនជ្រូកឡើងកំដៅ
- ប្រដាប់បន្តពូជហើម
- ចេញទឹករំអិលពណ៌ល្អក់តាមប្រដាប់បន្តពូជ
- ស្បែកឡើងលឿង

<u>ការព្យាបាល</u>

- ប្រើសូលុយស្យុងអំបិលដើម្បីលាងសម្អាតស្បូនដោយបាញ់ទឹកបញ្ចូលទៅក្នុងស្បូន
- ប្រើថ្នាំអង់ទីប្យូទិកដើម្បីព្យាបាល

*ជម្ងឺរលាកស្បូន:*

ជាជំងឺតែងតែកើតឡើងលើសត្វក្រោយកើតកូនដែលបណ្ដាលមកពីការកើតកូនមានរយៈពេលយូរ សុកមិនធ្លាក់ ឬធ្លាក់មិនអស់ និងការលូកដៃជួយបង្កើតកូន។

<u>រោគសញ្ញា</u>

- ជំងឺរលាកស្បូននេះច្រើនកើតក្នុងរយៈពេល ៤ ទៅ ៥ថ្ងៃក្រោយពេលកើតកូន
- បង្ហាញអាការៈឈឺចាប់
- ឡើងកំដៅខ្លួន (៤០ ទៅ ៤១អង្សាសេ)
- មេជ្រូកមិនសូវស៊ីចំណី
- សញ្ញាលាសដោះ និងទឹកដោះថយចុះ
- មេជ្រូកប្រឹងបន្ទោរបង់មិនឈប់ឈរ ដោយចំកោងខ្នង និងកន្ទែកជើងក្រោយទាំងពីរ
- ២-៣ថ្ងៃក្រោយមក មានទឹកពណ៌ល្អក់ក្រម៉ៅ ស្អុយរលួយ ហូរចេញតាមយោនី។
- មានហូរខ្ទុះតាមប្រដាប់បន្តពូជ និងមានបំណែកសុកមកជាមួយ។

<u>ការព្យាបាល</u>

- ប្រើ Permanganate de potassium លាយទឹក ១លីត្រ បាញ់តាមទុយោចូលទៅក្នុងស្បូនដើម្បីលាងសម្អាតរហូតទាល់តែវាមានទឹកពណ៌ខៀវហូរចេញមក ទើបឈប់ (ដោយលាង ១ថ្ងៃម្ដង ពេលមិនទាន់ជា និង ២ថ្ងៃម្ដង ពេលជ្រូកធូរស្បើយ)។
- ប្រើអង់ទីប្យូទិកដូចជា ទ្រីមេតូព្រីម ជាមួយស៊ុលហ្វា ឬអង់រ៉ូហ្វ្លុកសាក់ស៊ីន អុកស៊ីតេត្រាស៊ីគ្លីន រយៈពេល ៣ថ្ងៃ
- ចាក់ប្រូស្តាក្លង់ឌីន (ចាក់តែ១លើក)
- ពេលទឹកហូរចេញអស់ហើយ ត្រូវបញ្ចូលថ្នាំប៉េនីស៊ីលីនលាយជាមួយប្រេងសណ្ដែក ២ម.ល
- ដាក់ក្លរ៉ាសូនទៅក្នុងស្បូន ១ថ្ងៃពីរដង ម្ដង១គ្រាប់ (៣-៤ថ្ងៃ)

*ជម្ងឺរលាកដោះ*

ជំងឺនេះកើតឡើងលើមេជ្រូក ជាញឹកញាប់ក្រោយពីកើតកូនរួចបានពី ១២ ទៅ ៧២ម៉ោង។

<u>មូលហេតុ</u>

- របួសដោះដោយសារកូនជ្រូកខាំ ឬ ដោះកកិតនឹងបាតទ្រុង
- ទឹកដោះច្រើនពេក កូនជ្រូកបៅមិនអស់ធ្វើឱ្យទឹកនៅសល់កកក្នុងដោះដែលបៅ
- កូនតិចជាងចំនួនដោះ កូនបៅមិនអស់
- បណ្ដាលមកពីជំងឺផ្សេងៗ

រោគសញ្ញា

- ឡើងកំដៅខ្លួន (៤០-៤២អង្សា)
- ដោះហើមធំ ក្រហម រឹង និងក្ដៅ
- មេជ្រូកធាក់កូនចេញ ពេលវាដើរប៉ះឬបៅ
- ស៊ីតិច ឬ មិនស៊ីតែម្ដង ហើយដេកបែរទៅជញ្ជាំងមិនឱ្យកូនបៅ
- ពេលរលាកដំបូង ទឹកដោះនៅចេញ ហើយខាប់បន្តិចម្ដងៗ
- ទឹកដោះមានលាយខ្ទុះ ខាប់លឿង
- ករណីធ្ងន់ធ្ងរក្បាលដោះមានហូរចេញទឹកពណ៌លឿងលាយខ្ទុះ និង ឈាម

ការការពារ

- មុនកើត ១អាទិត្យ ត្រូវបន្ថយចំណីសំបូរជាតិសាច់
- ក្រោយកើតត្រូវលាងដោះមេជ្រូកទាំងពីរជួរនិងផ្នែកខាងក្រោយជាមួយទឹកក្ដៅឧណ្ហៗលាយសាប៊ូឲ្យបានពី ២ដង ទៅ៣ដងក្នុង១ថ្ងៃ
- ឱ្យកូនជ្រូកបៅឱ្យបានគ្រប់ដោះ ករណីបៅមិនអស់ត្រូវច្របាច់ទឹកដោះចេញឱ្យអស់
- កាត់ធ្មេញកូនជ្រូកចេញ
- ធ្វើអនាម័យទ្រុងឲ្យបានស្អាត

ការព្យាបាល

- ដំណាក់កាលរលាកដំបូងយកដុំទឹកកកលុញចុះឡើងលើដោះដែលរលាកទាល់តែដោះលែងហើម
- ប្រសិនបើដោះហើម ក្ដៅនិងឈឺត្រូវយកទឹកក្ដៅឧណ្ហបាញ់លើដោះ ឬយកក្រណាត់ជ្រលក់ទឹកក្ដៅឧណ្ហៗមកស្អំដោះ ២០-៣០នាទីឱ្យបានច្រើនដង
- មិនត្រូវឱ្យកូនជ្រូកបៅដោះដែលរលាកនោះ ហើយត្រូវច្របាច់ទឹកដោះចេញពីដោះដែលរលាកចោលឲ្យអស់ ឲ្យបាន ៣-៤ ដងក្នុង១ថ្ងៃ។
- ប្រើអង់ទីប្យូទីកចាក់ឲ្យមេជ្រូក: ចាក់ប៉ង់ស្ត្រឹបរយៈពេល ៣ ថ្ងៃ
- បើព្យាបាលមិនទាន់ពេល ដោះនឹងឡើងរឹង ហើយលែងមានទឹកដោះ

## ឧបសម្ព័ន្ធ ២៖ កម្មវិធីចាក់ថ្នាំការពារសុខភាពជ្រូក

ការចាក់ថ្នាំការពារ(ការចាក់វ៉ាក់សាំង) គឺជាមធ្យោបាយមួយក្នុងការការពារសត្វជ្រូកពីជំងឺឆ្លងផ្សេងៗ។ ការចាក់ថ្នាំការពារអាចធ្វើទៅបាននៅពេលសត្វមានសុខភាពល្អ។ ខាងក្រោមនេះគឺជាការណែនាំអំពីកម្មវិធីចាក់ថ្នាំការពារជម្ងឺឱ្យសត្វជ្រូក។

**តារាង១. កម្មវិធីចាក់វ៉ាក់សាំង**

| អាយុ | ប្រភេទវ៉ាក់សាំង | ការពារជំងឺ | របៀបប្រើ | កំរិតនៃការប្រើប្រាស់ |
|---|---|---|---|---|
| ១ថ្ងៃ | Porcine Coli | រាគកូនជ្រូក | ផឹក | ២ cc, ១ក្បាល |
| ២ថ្ងៃ | Enro 100 | សំលាប់បាក់តេរី | ចាក់/ផឹក | ០,២ cc, ១ក្បាល |
| ៣ថ្ងៃ | Vitamin $AD_3E$ | ជំនួយកំលាំង | ចាក់ IM | ០,៣ cc, ១ក្បាល |
| - | Fer Gentyl | ខ្វះជាតិដែក | ចាក់ IM | ១ cc, ១ក្បាល |
| - | Fer $B_{12}$ | ខ្វះជាតិដែក | ចាក់ IM | ១ cc, ១ក្បាល |
| ៧ថ្ងៃ | Rhini TX4 | សារទឹក កញ្ជ្រិល រលាកទងសួតលើកទី១ | ចាក់ IM | ១ cc, ១ក្បាល |
| ១៨ថ្ងៃ | Salmonella | ការពារជំងឺគ្រុនពោះវៀនលើកទី១ | ចាក់ IM | ១ cc, ១ក្បាល |
| ២២ថ្ងៃ | Rhini TX4 | សារទឹក កញ្ជ្រិល រលាកទងសួតលើកទី២ | ចាក់ IM | ២ cc, ១ក្បាល |
| ៣៣ថ្ងៃ | Ivomectin | ទំលាក់ព្រូន និងអង្កែ | ចាក់ SC | ១ cc, ១ក្បាល |
| ៣៥ថ្ងៃ | Salmonella | ការពារជំងឺគ្រុនពោះវៀនលើកទី២ | ចាក់ IM | ២ cc, ១ក្បាល |
| ៤០ថ្ងៃ | Pest Vaccine | ការពារជំងឺ ប៉េស្តលើកទី១ | ចាក់ IM | ២ cc, ១ក្បាល |
| ៤៥ថ្ងៃ | Survaxin | ការពារជំងឺឆ្អុត និង អូហ្សេស្គីលើកទី១ | ចាក់ IM | ២ cc, ១ក្បាល |
| ៦០ថ្ងៃ | Pest Vaccine | ការពារជំងឺ ប៉េស្តលើកទី២ | ចាក់ IM | ២ cc, ១ក្បាល |
| ៧០ថ្ងៃ | F.M.D | ការពារជំងឺអុតក្តាម | ចាក់ IM | ២ cc, ១ក្បាល |

### តារាង២. កម្មវិធីចាក់ថ្នាំការពារសម្រាប់មេជ្រូកពូជ

| ដំណាក់កាល | ការពារជម្ងឺ | ចំនួនដង |
|---|---|---|
| ១៥ថ្ងៃមុនបង្កាត់ | -ប៉េស្ត<br>-គ្រុនពោះវៀន (Salmonella) | -លើកទី១ |
| ១០ថ្ងៃមុនបង្កាត់ | -សារទឹក | -លើកទី១ |
| ១ខែមុនកើត | -គ្រុនពោះវៀន (Salmonella) | -លើកទី២ |
| ៤០ថ្ងៃក្រោយកើត | -គ្រុនពោះវៀន (Salmonella) | -លើកទី៣ |
| ៤៥ថ្ងៃក្រោយកើត | -ប៉េស្ត និង សារទឹក | -លើកទី២ |

### តារាង៣. កម្មវិធីចាក់ថ្នាំការពារសម្រាប់មេជ្រូកផើម

| ដំណាក់កាល | ការពារជម្ងឺ | ចំនួនដង |
|---|---|---|
| ៤០ថ្ងៃក្រោយបង្កាត់ | -គ្រុនពោះវៀន (Salmonella) | -លើកទី១ |
| ៤៥ថ្ងៃក្រោយបង្កាត់ | -ប៉េស្ត | -លើកទី១ |
| ៥០ថ្ងៃក្រោយបង្កាត់ | -សារទឹក | -លើកទី១ |
| ៣០ថ្ងៃក្រោយកើត | -គ្រុនពោះវៀន (Salmonella) | -លើកទី២ |
| ៤០ថ្ងៃក្រោយកើត | -សារទឹក | -លើកទី២ |
| ៤៥ថ្ងៃក្រោយកើត | -ប៉េស្ត | -លើកទី២ |

<u>ចំណាំ:</u>

- ចំពោះជ្រូកបាត្រូវចាក់ថ្នាំការពារជំងឺ ឡិបតូ (រលូត) និងកញ្ជ្រិល ឲ្យបាន២ដងក្នុង ១ឆ្នាំ។
- ចំពោះជ្រូកសាច់ ត្រូវបញ្ឈប់ការប្រើថ្នាំផ្សេងៗនិងវ៉ាក់សាំងឱ្យបាន ៣០ថ្ងៃយ៉ាងតិច មុននឹងកាប់សាច់។
- ចំពោះជ្រូកមេផើមក្នុងការប្រើវ៉ាក់សាំងគឺត្រូវមានការប្រុងប្រយ័ត្នខ្លាចរលូតកូន ដូច្នេះ មិនគួរប្រើវ៉ាក់សាំងប្រភេទវ៉ាក់សាំងរស់លើមេជ្រូកផើមឡើយ។
- រាល់ការព្យាបាល និងការចាក់ថ្នាំការពារជម្ងឺសត្វត្រូវធ្វើឡើងដោយអ្នកជំនាញដូចជា ភ្នាក់ងារសុខភាពសត្វភូមិ ឬមន្ត្រីបសុពេទ្យ។

## ឧបសម្ព័ន្ធ ៣៖ ការការពារការឆ្លងជម្ងឺពីសត្វជ្រូកទៅសត្វជ្រូក និងពីជ្រូក ទៅលើមនុស្ស

| |
|---|
| ជំនួយស្មារតី: វិធីសាស្រ្តការពារទូទៅ<br>➢ ចាក់វ៉ាក់សាំងជ្រូកឱ្យបានទៀងទាត់ (មើលក្នុងកម្មវិធីចាក់វ៉ាក់សាំង)<br>➢ ឱ្យជ្រូកស៊ីចំណីនិងផឹកទឹកស្អាតឱ្យបានគ្រប់គ្រាន់<br>➢ ធ្វើអនាម័យទ្រុង និងសម្ភារៈប្រើប្រាស់ផ្សេងៗទៀតដោយប្រើកំបោរ ស ឬថ្នាំសម្លាប់មេរោគផ្សេងៗទៀត<br>➢ ហាមអ្នកដទៃចេញចូលក្នុងទ្រុងជ្រូក<br>➢ សង់ទ្រុងជ្រូកឱ្យនៅដាច់ឆ្ងាយពីលំនៅដ្ឋាន<br>➢ ចិញ្ចឹមសត្វដាច់ដោយឡែកពីគ្នា<br>➢ អនុវត្តតាមវិធានការជីវសុវត្ថិភាព |

ខាងក្រោមនេះ គឺជាគោលការណ៍ណែនាំខ្លះៗអំពី ការការពារការឆ្លងជម្ងឺជ្រូកទៅលើមនុស្សៈ

- កុំបរិភោគសាច់ជ្រូកឈឺ ឬជ្រូកងាប់ដោយសារជម្ងឺ
- ដុត ឬកប់ចោលជ្រូកងាប់ដោយសារជម្ងឺតាមវិធានការបសុពេទ្យ
- ដុត ឬ កប់ចោលនូវកាកសំណល់ទាំងអស់របស់សត្វជ្រូកដែលងាប់ដោយសារជម្ងឺ
- ត្រូវលាងសម្អាតដៃនឹងសាប៊ូ និងថ្នាំសម្លាប់មេរោគក្រោយពីបះពាល់ជាមួយសត្វឈឺ

# ជំពូកទី ៧៖ ការវិភាគសេដ្ឋកិច្ច

<u>រយៈពេល:</u> កន្លះថ្ងៃ

<u>គោលបំណង</u>

- ឱ្យកសិករយល់ដឹងអំពីវិធីសាស្ត្រនៃការកត់ត្រាចំណាយ-ចំណូលក្នុងផលិតកម្ម
- ដើម្បីធ្វើវិភាគសេដ្ឋកិច្ច នៅពេលបញ្ចប់ការងារផលិតកម្ម (តើចំណេញ ឬ ខាត)

<u>សំភារៈ</u>

ក្រដាសផ្ទាំងធំ ប៊ិចហ្វឺត ស្កុត ឧបសម្ព័ន្ធ ១ (គំរូកត់ត្រាចំណាយ-ចំណូល) និង ឧបសម្ព័ន្ធ ២ (គំរូវិភាគសេដ្ឋកិច្ច)

<u>ដំណើរការ</u>

**សកម្មភាពទី ១៖** ការផ្តើមអំពីការវិភាគសេដ្ឋកិច្ច

១. សុំឱ្យកសិករដែលមានបទពិសោធន៍ប្រាប់កសិករដទៃទៀតក្នុងក្រុមអំពីរបៀបកត់ត្រាចំណាយផលិតកម្មចំណូល និងការគណនារកចំណេញ ឬខាត

២. សួរគាត់ថា តើហេតុអ្វីបានជាយើងត្រូវធ្វើការវិភាគសេដ្ឋកិច្ច?

៣. កត់ត្រាចម្លើយរបស់គាត់ ហើយបូកសរុប និងប្រៀបធៀបជាមួយជំនួយស្មារតីខាងក្រោម

ជំនួយស្មារតី: សារៈសំខាន់នៃ

<u>ការកត់ត្រាចំណាយ-ចំណូលលំអិតនៃផលិតកម្ម</u>

- ដើម្បីកត់ត្រាព័ត៌មានផ្សេងៗទាក់ទងនឹងផលិតកម្មឱ្យបានត្រឹមត្រូវ (ប្រសើរជាងការស្មាន) ដើម្បីអាចឱ្យកសិករមានលទ្ធភាពធ្វើការវិភាគសេដ្ឋកិច្ច
- សម្រាប់ជាព័ត៌មានដល់កសិករដទៃទៀត ឬសម្រាប់ក្រុមកសិករដើម្បីឱ្យពួកគាត់អាចប្រកបរបររួមគ្នា
- ជាមធ្យោបាយក្នុងការគ្រប់គ្រងសម្រាប់ឱ្យកសិករដឹងអំពីការរីកចម្រើននៃផលិតកម្មរបស់ខ្លួន

<u>ការវិភាគសេដ្ឋកិច្ច</u>

- ជួយឱ្យកសិករ អាចដឹងអំពីផលចំណេញ ឬ ខាត ដែលបានពីការចិញ្ចឹមជ្រូក
- ជាមធ្យោបាយជួយឱ្យអ្នកចិញ្ចឹមអាចធ្វើការប្រៀបធៀបការចិញ្ចឹមជ្រូកជាមួយនឹងមុខរបរផ្សេងៗទៀត
- ផ្តល់ព័ត៌មាន ដល់អ្នកចិញ្ចឹម ដើម្បីឱ្យគាត់រៀបចំគម្រោងផែនការថ្មី ឬការកែលម្អផលិតកម្មនាដំណាក់កាល ឬវដ្តបន្ទាប់ៗទៀត

**សកម្មភាពទី ២៖** ការកត់ត្រាចំណាយ-ចំណូលផលិតកម្ម និងការរកចំណេញ/ខាត

១. លើកយកគំរូនៃការកត់ត្រាចំណាយ-ចំណូល និងការរកចំណេញ/ខាត ជាលក្ខណៈប្រព័ន្ធសម្រាប់ដំណាក់កាលដំបូង នៃផលិតកម្ម (ការទិញកូនជ្រូក ផលិតកម្មជ្រូកសាច់ និងជ្រូកពូជ) មកបង្ហាញនិងពន្យល់ដល់កសិករ (មើលឧបសម្ព័ន្ធ ១)

២. បង្ហាញកសិករនូវគំរូកត់ត្រាលំហូរសាច់ប្រាក់សង្ខេបដែលត្រូវបានបំពេញរួចសម្រាប់មួយវដ្តផលិតកម្មដំបូង (មើលក្នុងឧបសម្ព័ន្ធ ២)

៣. ដឹកនាំកសិករបំពេញតារាងចំណាយ-ចំណូលសម្រាប់វដ្តទីពីរនៃផលិតកម្ម (អ្នកសម្របសម្រួលអាចជួយដល់គាត់ក្នុងករណីចាំបាច់)

៤. ប្រាប់ឲ្យកសិករគណនារកចំណេញ/ខាតសម្រាប់វគ្គទីមួយ និងទីពីរនៃផលិតកម្ម

៥. សួរកសិករថាហេតុអ្វីនៅក្នុងបន្ទាត់ជួរឈរទីមួយគេមិនឃើញមានផលចំណេញ?

៦. សួរកសិករថាតើគាត់ធ្វើយ៉ាងណាទើបអាចដោះស្រាយបាននូវទុនផលិតកម្មក្នុង១ឆ្នាំដំបូង?

៧. សួរកសិករថា ហេតុអ្វីបានជានៅក្នុងដំណាក់កាលទីពីរនៃផលិតកម្មទើបគាត់អាចទទួលបានផលចំណេញ?



**ជំនួយស្មារតី**

ប្រាប់កសិករថាសម្រាប់ការចិញ្ចឹមវគ្គដំបូងគឺតែងតែត្រូវចំណាយច្រើនដោយសារត្រូវចំណាយទៅលើការចាប់ផ្ដើមទាំងស្រុង។ តែសម្រាប់ការចិញ្ចឹមវគ្គបន្ទាប់ទៀតការចំណាយតិចជាង ហើយទទួលបានផលចំណេញច្រើនជាង។

**សកម្មភាពទី ៣៖** លទ្ធភាពដែលអាចរកបាននូវថវិកា និងការគ្រប់គ្រងថវិកា

១. សួរកសិករថា តើអ្នកណាដែលជាអ្នកទទួលបានផលចំណេញពីការចិញ្ចឹមជ្រូក (បុរស ឬ ស្ត្រី?)

២. សួរកសិករ ថាតើនរណាជាអ្នកគ្រប់គ្រងថវិកា និងជាអ្នកសម្រេច ក្នុងការបែងចែកផលប្រយោជន៍ពីមុខរបរចិញ្ចឹមជ្រូក (បុរស ឬ ស្ត្រី?)

៣. សួរកសិករថា តើគាត់គិតថាប្រព័ន្ធសម្រាប់ឱ្យគាត់ទទួលបានថវិកា និងគ្រប់គ្រងថវិកាដែលនិយាយតាំងពីខាងដើម មានភាពយុត្តិធម៌ទាំងសម្រាប់បុរស និងស្ត្រីដែរឬទេ?

៤. ដឹកនាំកសិករពិភាក្សាដើម្បីរកគំនិតយោបល់អ្វីក្នុងការធ្វើឱ្យក្រុមមានលទ្ធភាពទទួលបានថវិកា និងអាចគ្រប់គ្រងថវិកាបានកាន់តែប្រសើរ

## ឧបសម្ព័ន្ធ ១៖ វិធីសាស្រ្តកត់ត្រាចំណាយ-ចំណូល

១. គំរូកត់ត្រាចំណាយ

| ថ្ងៃ-ខែ-ឆ្នាំ | ប្រភេទចំណាយ | ចំនួន/ឯកតា | តំលៃរាយ (រៀល) | តំលៃសរុប (រៀល) |
|---|---|---|---|---|
| ១-១២/១០/២០១០ | ឧទា:<br>សំភារ:<br>ទ្រុង<br>ស្នូក<br>-ចំណី<br>-ទឹក | <br><br><br><br>១<br>១ | <br><br><br><br>៣០០០<br>៥០០០ | <br><br>២៨៥.០០០<br><br>៣.០០០<br>៥.០០០ |
| ២៣/១០/២០១០ | ជ្រូក<br>-កូនជ្រូក | <br>២ | <br>១៥០.០០០ | <br>៣០០.០០០ |
| ២០/១០/២០១០ | ចំណី<br>ត្រកួន<br>កន្ទក់ | ៣០០ គីឡូ<br>--<br>១០០ គ.ក្រ<br>--- | ២៥០០<br>៥០.០០០<br>៨០០ | ៧៥០.០០០<br>៥០.០០០<br>៨០.០០០ |
| | ថ្នាំការពារ | ៨ | ៤០០០ | ៣២.០០០ |
| ---------- | ---------- | ---------- | ---------- | ---------- |
| ចំណាយសរុប | | | | **១.៥០៥.០០០** |

២. គំរូកត់ត្រាចំណូល

| ថ្ងៃ-ខែ-ឆ្នាំ | ប្រភេទចំណូល | ចំនួន/ឯកតា | តំលៃរាយ (រៀល) | តំលៃសរុប (រៀល) | ផ្សេងៗ |
|---|---|---|---|---|---|
| | <u>លក់:</u><br>-ជ្រូកសាច់ | ១៥០ គ.ក្រ | ៩.០០០ | ១.៣៥០.០០០ | |
| ចំណូលសរុប | | | | ១.៣៥០.០០០ | |

៣. ការគណនារកចំណេញ ឬ ខាត

<u>រូបមន្តរកចំណេញឬខាត:</u>

| |
|---|
| ចំណូលសរុប-ចំណាយសរុប=ចំណេញ ឬ ខាត (ចំណេញ ឬ រួចខ្លួន ឬ ខាត) |

<u>**កំណត់សំគាល់:**</u> ផលពីការលក់អាចចំណេញ(ពេលលទ្ធផលវិជ្ជមាន) ឬ ខាត (ពេលលទ្ធផលអវិជ្ជមាន)

## ឧបសម្ព័ន្ធ ២៖ ការកត់ត្រាលំហូរសាច់ប្រាក់ និង វិភាគសេដ្ឋកិច្ច៖ ការកត់ត្រាលំហូរសាច់ប្រាក់មួយវដ្តផលិតកម្ម (៣ ខែ)

| ខែ / ចំណូល/ចំណាយ | ដំណាក់កាលចាប់ផ្តើមផលិត | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | សរុប |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| **ចំណូល** | | | | | | | | | | | | | | |
| លក់មេជ្រូក(២) | ០ | ៨០០០០០ | ៨០០០០០ | ៨០០០០០ | ៨០០០០០ | ៨០០០០០ | | | | | | | | |
| លក់ជ្រូកក្រមុំ (០) | ០ | ០ | ០ | ០ | ០ | ០ | | | | | | | | |
| លក់ជ្រូកសាច់ (១០) | ០ | ៣០០០០០០ | ៣០០០០០០ | ៣០០០០០០ | ៣០០០០០០ | ៣០០០០០០ | | | | | | | | |
| លក់ជ្រូកបា (០) | ០ | | | | | | | | | | | | | |
| ប្រាក់កម្ចី | ១២០០០០០០ | | | | | | | | | | | | | |
| ក) ចំណូលសរុប | **១២០០០០០០** | **៣៨០០០០០** | **៣៨០០០០០** | **៣៨០០០០០** | **៣៨០០០០០** | **៣៨០០០០០** | | | | | | | | |
| **ចំណាយ** | | | | | | | | | | | | | | |
| ចំណាយចាប់ផ្តើម: | | | | | | | | | | | | | | |
| ទ្រុង | ៤០០០០០០ | | | | | | | | | | | | | |
| ស្នូកទឹក | ១០០០០០ | | | | | | | | | | | | | |
| ស្នូកចំណី | ១០០០០០ | | | | | | | | | | | | | |
| មេជ្រូកពូជ(៣) | ១៨០០០០០ | | | | | | | | | | | | | |
| កូនជ្រូកពូជ (០) | ០ | | | | | | | | | | | | | |

| | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ជ្រូកបា (១) | ១០០០០០០ | | | | | | | | | | | | | |
| ផ្សេងៗ | ០ | | | | | | | | | | | | | |
| **ចំណាយចាប់ផ្តើមសរុប** | **៦៨០០០០០** | **០** | **០** | **០** | **០** | **០** | | | | | | | | |
| ការថែទាំ: | | | | | | | | | | | | | | |
| ចំណី: | | ១០០០០០០ | ១០០០០០០ | ១០០០០០០ | ១០០០០០០ | ១០០០០០០ | | | | | | | | |
| កន្ទក់ | | | | | | | | | | | | | | |
| ចុងអង្ករ | | | | | | | | | | | | | | |
| ត្រីក្រៀម | | | | | | | | | | | | | | |
| ពោតក្រហម | | | | | | | | | | | | | | |
| សណ្តែកសៀង | | | | | | | | | | | | | | |
| អំបិល | | | | | | | | | | | | | | |
| ព្រីមិច | | | | | | | | | | | | | | |
| ថ្នាំការពារ | | ៤០០០០ | ៤០០០០ | ៤០០០០ | ៤០០០០ | ៤០០០០ | | | | | | | | |
| ចំណាយឧបត្ថម្ភធន | | | | | | | | | | | | | | |
| ខ) ចំណាយសរុប | **៦៨០០០០០** | ១០៤០០០០ | ១០៤០០០០ | ១០៤០០០០ | ១០៤០០០០ | ១០៤០០០០ | | | | | | | | |
| ចំណេញ/ខាត (ក-ខ) | -៦៨០០០០០ | **២៧៦០០០០** | **២៧៦០០០០** | **២៧៦០០០០** | **២៧៦០០០០** | **២៧៦០០០០** | | | | | | | | |
| លំហូរសាចប្រាក់ (លំហូរសាច់ប្រាក់ដំណាក់ កាលដំបូង +¼- ផលដុលបច្ចុប្បន្ន) | -៦៨០០០០០ | -៤១៤០០០០ | -១៣៨០០០០ | ១៣៨០០០០ | ៤១៤០០០០ | ៦៩០០០០០ | | | | | | | | |

## ជំពូកទី ៨៖ ផលប៉ះពាល់នៃការចិញ្ចឹមជ្រូកលើបរិស្ថាន

រយៈពេល: ១ ម៉ោង ៣០នាទី

គោលបំណង:

-ឱ្យកសិករយល់ដឹងអំពីផលប៉ះពាល់នៃការចិញ្ចឹមជ្រូក លើសុខុមាលភាពមនុស្ស និងសត្វផ្សេងៗទៀត

-ឱ្យកសិករចេះវិធានការណ៍ជីវសុវត្ថិភាពក្នុងការចិញ្ចឹមជ្រូក

សំភារ: ក្រដាសផ្ទាំងធំ ហ្វឺត ស្កុត

ដំណើរការ:

សកម្មភាពទី ១៖ ការពិភាក្សាអំពី "បរិស្ថាន"

១. សួរកសិករថា តើពាក្យថា "បរិស្ថាន" មានន័យដូចម្តេច?

២. តើវាផ្តល់ផលប៉ះពាល់យ៉ាងដូចម្តេចខ្លះនៅពេលដែលបរិស្ថានត្រូវបានបំពុល?

៣. ផ្តល់ចម្លើយត្រឹមត្រូវដល់គាត់ដោយយកតាម ជំនួយស្មារតី ខាងក្រោម

**ជំនួយស្មារតី: និយមន័យបរិស្ថាន និង ទំនាក់ទំនងរបស់វាក្នុងកន្លែងចិញ្ចឹមជ្រូក**

បរិស្ថាន

បរិស្ថាន គឺជាបរិយាកាសជុំវិញដែលក្នុងនោះរួមមានវត្ថុមានជីវិត និងអត់ជីវិត។

ការបំពុលបរិស្ថាន

គឺជាដំណើរការធ្វើឱ្យកខ្វក់នូវមជ្ឈដ្ឋានរស់នៅរបស់មនុស្ស សត្វដែលវាបង្កឱ្យមានផលលំបាកមួយចំនួនដល់ការរស់នៅប្រចាំថ្ងៃដូចជា: ជំងឺ ក្លិន ចំណីអាហារមានភាពកខ្វក់ប៉ះពាល់សតិអារម្មណ៍របស់មនុស្ស...

បរិស្ថានក្នុងការងារចិញ្ចឹមជ្រូក:

ក្នុងការងារចិញ្ចឹមជ្រូក បរិស្ថានដែលយើងត្រូវស្គាល់រួមមាន ចំណី ទ្រុង មេរោគ រុក្ខជាតិ សត្វ មនុស្ស ទឹក ដី និងខ្យល់។

**សម្មភាពទី ២៖** ការការពារផលប៉ះពាល់នៃការចិញ្ចឹមជ្រូកលើបរិស្ថាន

១. សួរទៅកសិករថាតើការចិញ្ចឹមបង្កឱ្យមានផលប៉ះពាល់អ្វីខ្លះដល់ការរស់នៅរបស់មនុស្ស?

២. កត់ត្រាចម្លើយរបស់ពួកគាត់ នៅលើក្រដាសផ្ទាំងធំ

៣. ប្រាប់កសិករអំពីផលប៉ះពាល់បរិស្ថាននៃការចិញ្ចឹមជ្រូក ព្រមទាំងវិធានការការពារខ្លះៗ (មើលជំនួយស្មារតី)

**ជំនួយស្មារតី: ការចិញ្ចឹមជ្រូក និងបរិស្ថាន**

<u>ផលប៉ះពាល់លើបរិស្ថាន:</u>

-បង្កក្លិនមិនល្អដល់ការរស់នៅរបស់មនុស្ស
-បង្កសំលេងរំខានដល់ការរស់នៅរបស់មនុស្ស
-ចម្លងជំងឺផ្សេងៗដល់មនុស្ស និងសត្វចិញ្ចឹមផ្សេងៗទៀត
-បង្កភាពកខ្វក់ដល់ប្រភពទឹកប្រើប្រាស់

<u>វិធានការណ៍ការពារ</u>

-ចិញ្ចឹមជ្រូកក្នុងទ្រុង (មើលបន្ថែមក្នុងការសាងសង់ទ្រុង)
-ធ្វើអនាម័យឱ្យបានស្អាត បោសកើបលាមក និងកាកសំណល់របស់ជ្រូកដាក់ក្នុងរណ្តៅ
-កប់ ឬដុតកម្ទេចសាកសព និងកាកសំណល់របស់ជ្រូកឈឺ (មើលបន្ថែមក្នុងមេរៀនស្តីអំពីការថែទាំសុខភាពជ្រូក)
-លាងសម្អាតសំភារៈចិញ្ចឹមជ្រូកឱ្យបានជាប្រចាំ ស្នូកទឹក ស្នូកចំណី និងសំភារៈផ្សេងៗ ទៀត
-បាញ់ថ្នាំសម្លាប់មេរោគលើទ្រុង និងសំភារៈដែលប្រើប្រាស់សម្រាប់ចិញ្ចឹមជ្រូក
-បំបែកជ្រូកឈឺចេញពីជ្រូកជា
-រាយការណ៍ជូនភ្នាក់ងារសុខភាពសត្វភូមិ ឬមន្ត្រីផលិតកម្ម និងបសុព្យាបាលក្នុងករណីមានជ្រូកឈឺ និងងាប់ច្រើនដោយមិនដឹងពីមូលហេតុច្បាស់លាស់
-...................................

# ឯកសារយោង

១. Johan van't Klooster and Arie Wingelaar (2011) Pig farming in the tropics, *From free range to small-scale intensive production system.* Sixth completely revised edition. Agromisa Foundation and CTA, Wageningen, 2011. Netherland.

២. បណ្ឌិត ជា ណេង (១៩៩៧) បច្ចេកទេសចិញ្ចឹមជ្រូកជាលក្ខណៈគ្រួសារ

៣. J.A. Eusebio (1987) Pig production in the tropics, *Intermediate tropical agriculture series*. University of the Philippines at Los Banos. Printed in Hongkong.

៤. USAID សហការជាមួយ*នាយកដ្ឋានផលិតកម្ម និងបសុព្យាបាល (២០១១)*បច្ចេកទេសចិញ្ចឹមជ្រូកជាលក្ខណៈគ្រួសារ

៥. USAID សហការជាមួយ (2011)*:* បច្ចេកទេសផ្សំចំណីជ្រូកដោយប្រើប្រាស់វត្ថុធាតុដើមក្នុងស្រុក

៦. មន្ទីរកសិកម្មខេត្តព្រៃវែង (២០១១) បច្ចេកទេសកសិកម្ម